00623039

F13

**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ២)

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស និងខ្មែរ (បកប្រែ)

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:

ស្ថានភាពនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 12 / 11 / 2010
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណង**

**ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី - ក្រុម ២**

<u>ដាក់ដោយ</u>៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

ជំនួយការ ៖

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រឹម

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រម Motoo NOGUCHI

ចៅក្រម Agnieska KLONOWIECKA-

00623040

F13

លោកស្រី Gunda MEYER
លោកស្រី Gillian QUANDT
លោកស្រី C. SANDOVAL VILLALBA
លោក Sylvain AUBRY
លោកស្រី Evie FRANCQ
លោកស្រី Fiona ILIFF
លោក Andrew SIREL
លោកស្រី Elena Birchall

ផ្ញើជូន ៖

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew T. CAYLEY

MILART
ចៅក្រម Chandra Nihal JAYASINGHE

**ជនជាប់ចោទ៖**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**សហមេធាវីការពារក្តីជនជាប់ចោទ**
លោក ការ សាវុត្ថ
លោក កង ឫទ្ធារី

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក គឹម ម៉េងឃី
លោកស្រី ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Phillipe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោក Pierre-Olivier SUR
លោកស្រី ទី ស្រីនណា
លោក Karim KHAN
លោក Alain WERNER
លោកស្រី Brianne McGONIGLE
លោកស្រី Fabienne TRUSSES-NAPRUS
លោកស្រី Christine MARTINEAU

00623041



## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១. នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង *("អ.ជ.ស.ដ")* បានប្រកាសសាលក្រម[1] ប្រឆាំងនឹងឈ្មោះ កាំង ហ្កេកអ៊ាវ។ ក្នុងផ្នែកទី៤ នៃសាលក្រមនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសម្រេចពីបុរេលក្ខខណ្ឌនៃការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី[2] និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់[3]។

២. តាមរយៈសេចក្តីសន្និដ្ឋានរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ជាទូទៅនូវទម្រង់នៃសំណងយោងតាមវិធានផ្ទៃក្នុង ("IR")[4] ។ បន្ថែមពីលើនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) បានកំណត់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនត្រឹមសំណើសុំសំណងជាក់លាក់ក្នុងក្របខណ្ឌនៃសំណើទូទៅនេះ[5]។ បណ្តឹងសាទុក្ខនេះកំណត់ត្រឹមតែសំណើ ដែលត្រូវបានបដិសេធនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងផ្នែកដែលត្រូវបានបដិសេធនៃសំណើសុំចងក្រងសេចក្តីថ្លែងសុំអភ័យទោសនៃសារណារួម។

៣. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំដូចខាងក្រោម[6] ៖

---

[1] សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 (បន្ទាប់ពីនេះហៅថា៖ សាលក្រម)។

[2] អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃឡើងវិញនូវលទ្ធភាពទទួលយកពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែល ក.ស.ច.ស បានទទួលស្គាល់រួចហើយ។ វិធានផ្ទៃក្នុងខ្វះចន្លោះនៅដំណើរការទទួលស្គាល់ពីរដំណាក់កាល ដែលបង្ហាញថាវិធីសាស្ត្រនេះពុំមានចែងក្នុងវិធានផ្ទៃក្នុង។

[3] សាលក្រម, កថាខណ្ឌ៦៣៥-៦៧៥។

[4] "សារណារួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង", ឯកសារ E159/3 ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ (បន្ទាប់ពីនេះហៅថា៖ សារណារួម)។

[5] ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២), ឯកសា E 159/6, ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៩, កថាខណ្ឌ១៤-២១ (បន្ទាប់ពីនេះយោងដោយ៖ សេចក្តីសន្និដ្ឋានបញ្ចប់)។

[6] បណ្តឹងសាទុក្ខនេះកំហិតត្រឹមសំណើដែលត្រូវបានបដិសេធដែលបានរៀបរាប់។ សូមមើលសំណើលម្អិតនៅក្នុងសារណារួម, សូមមើល យោងខាងលើ កំណត់សម្គាល់៤ និង៥។

- សំណើទី១៖ ការចងក្រង និងការផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោស រួមទាំងយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសូមអភ័យទោសទាំងអស់នេះ[7]
- សំណើទី២៖ ការសរសេរលិខិតទៅកាន់រដ្ឋាភិបាលស្នើសុំការសូមអភ័យទោសជាផ្លូវរដ្ឋ[8]
- សំណើទី៣ និងទី៤៖ ការកសាងបូជនីយដ្ឋាននៅមន្ទីរ ស-២១ និងជើងឯក និងការប្រែក្លាយព្រៃសទៅជាទីបូជនីយដ្ឋាន[9]។
- សំណើទី៥៖ ការផ្តល់សោហ៊ុយដល់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការធ្វើទស្សនកិច្ចទៅតាមបូជនីយដ្ឋាននានា[10]
- សំណើកទី៦៖ ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី[11]
- សំណើទី៧៖ ការថតសំឡេង និថតវីដេអូ និងការផ្សព្វផ្សាយអំពីការជំនុំជម្រះ[12]
- សំណើទី៨៖ ការយកឈ្មោះជនរងគ្រោះទៅដាក់លើអគារសាធារណៈចំនួន ១៧ និងការរំឭកដល់ជនរងគ្រោះ [13]
- សំណើទី៩៖ ការសរសេរលិខិតទៅរដ្ឋាភិបាលស្នើសុំយកថ្លៃចូលទស្សនាមន្ទីរ ស-២១ និងជើងឯកមួយផ្នែកសម្រាប់ជាសំណង[14]។

៤. ក្នុងសាលក្រមស្តីពីសំណងរបស់ខ្លួន អ.ជ.ស.ដ បានទទួលស្គាល់តែសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំឱ្យដាក់បញ្ចូលឈ្មោះរបស់ពួកគាត់ និងឈ្មោះជនរងគ្រោះផ្ទាល់ទៅក្នុង

---

[7] សារណារួម, កថាខណ្ឌ៤៥។

[8] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ៩-១៤។

[9] សេចក្តីសន្និដ្ឋានបញ្ចប់ កថាខណ្ឌ១៥, ១៦។

[10] សេចក្តីសន្និដ្ឋានបញ្ចប់ កថាខណ្ឌ១៧។

[11] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៨។

[12] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៩។

[13] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ២០។

[14] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ២១។

សាលក្រមស្ពាពរ រាប់ទាំងសេចក្តីបញ្ជាក់អំពីទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរ ស-២១ និងការចងក្រង និងបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោស ដែលបានធ្វើឡើងដោយ កាំង ហ្កេកអ៊ាវ នៅលើគេហទំព័រ អ.វ.ត.ក[15]។ អ.ជ.ស.ដ បានបដិសេធ ផ្នែកទី២នៃសំណើនេះ[16] ដែលបានស្នើសុំឱ្យបញ្ចូលសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះការសូមអភ័យទោសនោះ[17]។

៥. សារណានេះគឺធ្វើឡើងតាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណីខាងក្រោម៖ លោក ប៊ូ ម៉េង (D25/1), លោកស្រី ឈិន ណាវី (D25/2), លោក ជុំ ម៉ី (D25/3), លោក ជុំ ស៊ីវ៉ាត (D25/6), លោកស្រី ភីង ហ្គុតស៊ុនថាវី (D25/5), លោកស្រី អ៊ុំ ស៊ុន្ទី (D25/7), លោក តាត់ ឡន (D25/21), លោក ស៊ាង វ៉ាន់ឌី (D25/13), លោកស្រី អៀម សួយ (E2/21), លោក ស៊ីន លីមសៀ (E2/25), លោកស្រី អ៊ិល សាយ ហៅ រៀម (E2/24), លោកស្រី ពេញ សុខេន (E2/66), និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ខាងក្រោម ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងបដិសេធពុំទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ណាំ ម៉ុន (E2/32), លោកស្រី ឆាយ កន ហៅ លៀង កន (E2/35), លោកស្រី ហុង សាវ៉ាត (E2/83), លោក ឈឹម ស៊ីថា (E2/22) និងលោកស្រី ញ៉ិប គីម ស្រ៊ា (E2/64)។

៦. នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ដោយមានសេចក្តីសង្ខេបអំពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍[18]។

---

[15] យោងខាងលើ កំណត់សម្គាល់១ កថាខណ្ឌ៦៦៧, ៦៦៨, ៦៨៣។

[16] សូមមើល សារណារួម, ជើងទំព័រ៤ កថាខណ្ឌ៤៥។

[17] យោងខាងលើ កំណត់សម្គាល់១ កថាខណ្ឌ៦៦៨។

[18] សេចក្តីជូនដំណឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី២) លើសាលក្រមទាក់ទិននឹងសំណុំរឿង, ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/14។

៧. ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មវិធានផ្ទៃក្នុងជាធរមាន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានប្រើប្រាស់វិធីសាស្ត្ររបស់ អ.ជ.ស.ដ ក្នុងការយកវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៣ មកអនុវត្ត លើកលែងតែបរិបទបញ្ជាក់ផ្សេងពីនេះ[19]។

៨. បណ្តឹងសាទុក្ខនេះទាមទារឱ្យមានការច្រានចោលនូវសាលក្រមត្រង់ផ្នែកស្តីពីសំណង ដែលត្រូវបាន បដិសេធ។

## II. ច្បាប់ និងវិធានពាក់ព័ន្ធ

៩. ច្បាប់ និងវិធានផ្ទៃក្នុងពាក់ព័ន្ធដែលបណ្តឹងសាទុក្ខនេះយោង គឺវិធាន២១ វិធាន២៣ វិធាន៧២ វិធាន៨៣ វិធាន១០០ វិធាន១០១ វិធាន១០៤ វិធាន១០៥ វិធាន១០៦ និងវិធាន១០៧ នៃវិធានផ្ទៃក្នុង និងមាត្រា២០ថ្មី មាត្រា២៣ថ្មី មាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអំឡុងរយៈកាលរបបកម្ពុជាប្រជាធិប តេយ្យ[20] (*"ច្បាប់ អ.វ.ត.ក"*)។

## III. បទដ្ឋាននៃបណ្តឹងសាទុក្ខ

១០. យោងតាមវិធាន ១០៤(១)(ក) និង(ខ)នៃវិធានផ្ទៃក្នុង បទដ្ឋានសម្រាប់អង្គជំនុំជម្រះតុលាការកំពូល ទាក់ទងនឹងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខប្រឆាំងទៅនឹងសាលក្រម ឬសេចក្តីសម្រេចណា មួយរបស់ អ.ជ.ស.ដ គឺនៅពេលមានអត្ថិភាពនៃ "(ក) កំហុសអង្គច្បាប់ ដែលនាំឱ្យមោឃៈសាល ក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះ ឬ (ខ) កំហុសអង្គហេតុ ដែលនាំឱ្យសាលក្រមលើអង្គ សេចក្តីមិនយុត្តិធម៌"។

---

[19] យោងខាងលើ កំណត់សម្គាល់លេខ១ កថាខណ្ឌ៦៣៥ ដោយមានការពន្យល់បន្ថែមក្នុងជើងទំព័រ១០៦១ នៃសាលក្រម។

[20] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ នៅលើគេហទំព័រ៖ http://www.eccc.gov.kh/english/cabinet/law/4/KR_Law_as_amended_27_Oct_2004_Eng.pdf ។

១១. វិធាន១០០(១) ដែលមានចំណងជើងថា "ការសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី" គូសបញ្ជាក់ថា "អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះត្រូវសម្រេចអំពីភាពដែលអាចទទួលយកបាន និងខ្លឹមសារនៃការទាមទារចំពោះជនជាប់ចោទ"។ ដូច្នេះវិធានផ្ទៃក្នុងចាត់ទុកការសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីថាជាផ្នែកមួយនៃសាលក្រម។ ដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមសន្និដ្ឋានថាវិធានស្តីពី *បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម* ពិតជាត្រូវយកមកអនុវត្ត។

១២. ដូច្នេះ បទដ្ឋាននៃការពិនិត្យមើលឡើងវិញត្រូវបានកំណត់ត្រឹម "...ក) កំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសាលក្រម ឬសេចក្តីសម្រេច ឬ ខ) កំហុសអង្គហេតុដែលនាំឱ្យសាលក្រមលើអង្គសេចក្តីមិនយុត្តិធម៌"។

## IV. ការទទួលយកបណ្តឹងសាទុក្ខ

១៣. យោងតាមវិធាន១០៥(១) នៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខអាចធ្វើឡើងដោយ "គ) ***ជនរងគ្រោះ*** ពាក់ព័ន្ធនឹងសិទ្ធិរបស់ពួកគាត់តាមវិធាន២៣(៤) និង គ) [sic] ***ដើមបណ្តឹងរដ្ឋប្បវេណី*** ចំពោះផលប្រយោជន៍រដ្ឋប្បវេណីដទៃទៀតរបស់ពួកគេ ប៉ុន្តែអាចធ្វើបានតែក្នុងករណីដែលមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក្នុងរឿងនោះតែប៉ុណ្ណោះ" (មានបន្ថែមការបញ្ជាក់សេចក្តី)។ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[21]។ ដូច្នេះបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងការសម្រេចលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីគឺអាចទទួលយកបាន ដោយហេតុថាភាគីព្រះរាជអាជ្ញាបានដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមនេះដែរ។

១៤. នីតិវិធី និងពេលវេលាកំណត់ជាធរមាន អនុវត្តតាមវិធាន១០៥ (៣) និង១០៧ (៤) នៃវិធានផ្ទៃក្នុងដែលអនុញ្ញាតឲ្យផ្តល់ការជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ យោងតាមវិធាន១០៧ (៤) នៃវិធានផ្ទៃក្នុង។

---

[21] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូងក្នុងករណីរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច, ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/2។

វិធាននេះចែងថានៅពេលភាគីណាមួយបានប្ដឹងសាទុក្ខ ភាគីផ្សេងៗមានរយៈពេលបន្ថែមចំនួន១៥ថ្ងៃក្រោយពេលវេលាកំណត់បឋមដែលមានរយៈពេល៣០ថ្ងៃ។ ពេលវេលាកំណត់បឋមបានផុតកំណត់នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០។ ដូច្នេះ ពេលវេលាកំណត់សម្រាប់ការជូនដំណឹងស្ដីពីបណ្ដឹងសាទុក្ខបានផុតកំណត់នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០។ សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានដាក់នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០[22] គឺមិនទាន់ហួសពេលវេលាផុតកំណត់ឡើយ។ សារណាបណ្ដឹងសាទុក្ខដែលមានមូលដ្ឋាននេះត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃ នៃកាលបរិច្ឆេទក្នុងការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។ ពេលវេលាផុតកំណត់នៃសារណាបណ្ដឹងសាទុក្ខនេះផុតកំណត់នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០។ ដូច្នេះបណ្ដឹងសាទុក្ខនេះត្រូវបានដាក់ទាន់ពេលវេលា។

១៥. លើសពីនេះ បណ្ដឹងសាទុក្ខនេះធ្វើឡើងតាងនាមឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៥រូប ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានបដិសេធ។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នេះ បានប្ដឹងសាទុក្ខទៅលើសាលក្រមស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[23]។ ប្រសិនបើបណ្ដឹងសាទុក្ខរបស់ពួកគាត់បានជោគជ័យដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នឹងហួសពេលវេលាកំណត់សម្រាប់ "បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមស្ដីពីសំណង" ដូច្នេះពេលនោះ ពួកគាត់នឹងពុំមានលទ្ធភាពប្ដឹងសាទុក្ខជំទាស់នឹងការសម្រេចអំពីសំណងនេះឡើយ។

១៦. យើងបានសម្គាល់ឃើញថាវិធាន១០៥ (១) នៃវិធានផ្ទៃក្នុង បានប្រើប្រាស់ពាក្យខុសៗគ្នាដើម្បីសម្គាល់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ដូចជាពាក្យថាជាជនរងគ្រោះដែលប្ដឹងសាទុក្ខជំទាស់នឹងការសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមវិធាន២៣(៤) ឬជាដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់ទៅនឹងការសម្រេចអំពីសំណង។ ប្រសិនបើពាក្យទាំងអស់នេះត្រូវបានយកមកប្រើប្រាស់ហ្មត់ចត់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំង៥រូប ដែល

---

[22] កថាខណ្ឌ៦ នៃបណ្ដឹងសាទុក្ខនេះ។

[23] បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/6។

00623047

F13



ពាក្យសុំរបស់ពួកគាត់ត្រូវបានបដិសេធ ពុំអាចប្ដឹងសាទុក្ខទៅនឹងការសម្រេចអំពីសំណាងបានឡើយ ដោយហេតុថាមានតែដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យប្ដឹងសាទុក្ខ។

១៧. ការសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសាលក្រម ពុំមានចែងនៅក្នុងវិធានផ្ទៃក្នុងឡើយ។ ផ្ទុយទៅវិញ ការចេញសេចក្ដីសម្រេចស្ដីពីការ(មិន) ទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសាលក្រមគឺពុំស្របតាមវិធានផ្ទៃក្នុងឡើយ ហើយប្រឆាំងនឹងផលប្រយោជន៍យុត្តិធម៌ថែមទៀតផង។ សេចក្ដីសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវចេញពីដើមដំបូង និងយ៉ាងយូរបំផុតក្នុងពេលសវនាការបឋម ដូចមានចែងក្នុងវិធាន៨៣ (១) ដើម្បីអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំអាចអនុវត្តសិទ្ធិចូលរួមរបស់ពួកគាត់ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី។ សិទ្ធិចូលរួមរបស់ពួកគាត់មិនអាចអនុវត្តបានឡើយ ប្រសិនបើពួកគាត់ពុំត្រូវបានតុលាការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី។

១៨. ទោះបីជាយ៉ាងដូច្នេះក្ដី អង្គជំនុំជម្រះសាលាដំបូងបានសម្រេចអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី **នៅក្នុង** សាលក្រមរួចទៅហើយ។ ដូច្នេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយ ដែលពាក្យសុំរបស់ពួកគាត់ត្រូវបានបដិសេធ នឹងពុំមានមធ្យោបាយផ្លូវច្បាប់ណាមួយ ជំទាស់នឹងការបដិសេធសំណាងនេះឡើយ។

១៩. ដូច្នេះសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមសន្និដ្ឋានថា តាមរយៈភាពស្រដៀងគ្នាទៅនឹងវិធានផ្ទៃក្នុងដែលមានស្រាប់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក៏មានសិទ្ធិប្ដឹងសាទុក្ខ ជំទាស់ទៅនឹងការសម្រេចអំពីសំណាងនេះដែរ នៅពេលមានបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

២០. ដូច្នេះ សារណាបណ្ដឹងសាទុក្ខនេះធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាសំណាងនេះ និងត្រូវបានដាក់ជូនទាន់ពេលវេលាកំណត់។

## V. កំណត់សម្គាល់បឋម

២១. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា រដ្ឋគឺជាអ្នកទទួលខុសត្រូវលើសំណង[24]។ "អនុលោមតាមគោលការណ៍ជាហូរហែររបស់រដ្ឋក្នុងច្បាប់អន្តរជាតិ ការទទួលខុសត្រូវមានអត្ថិភាព ដោយមិនគិតអំពីពេលមានការផ្លាស់ប្ដូររដ្ឋាភិបាលឡើយ ហើយបន្តមានអត្ថិភាពចាប់ពីពេលមានអំពើដែលបង្កើតការទទួលខុសត្រូវនោះ រហូតដល់ពេលមានការប្រកាសថាអំពើនោះល្មើសនឹងច្បាប់"[25]។

២២. សិទ្ធិទទួលសំណងត្រូវបានបញ្ជាក់អះអាងដោយសន្ធិសញ្ញាផ្សេងៗ[26], ស្ថាប័នអង្គការសហប្រជាជាតិ[27], តុលាការតំបន់[28] ព្រមទាំងលិខិតុបករណ៍មួយចំនួន[29]។ វាជាកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិមួយ ដែលគេត្រូវចាត់ការលើអំពើខុសច្បាប់ជាអន្តរជាតិឱ្យបានពេញទំហឹង[30]។

---

[24] អត្ថបទស្រាវជ្រាវរបស់ Lisa Magarell, មានចំណងជើងថា "Reparations in Theory and Practice", នៅក្នុង៖ International Center for Transitional Justice (ប្រែសម្រួល), បោះពុម្ពដោយ Reparative Justice Series, ទំព័រ១០។

[25] តុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (Inter American Court on Human Rights) (IACHR), រឿងក្ដី Velásquez-Rodriguez តទល់នឹង Honduras, សាលក្រមចុះថ្ងៃទី២៩ ឆ្នាំ១៩៨៨ (អង្គសេចក្ដី), លេខស៊េរី 4, កថាខណ្ឌ 184។

[26] ឧទារណ៍, កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិនយោបាយ (ICCPR) (១៩៦៦) (មាត្រា២(៣),៩(៥) និង១៤(៦)។ អនុសញ្ញាអន្តរជាតិស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) (1965) (មាត្រា៦)។ អនុសញ្ញាស្ដីពីសិទ្ធិកុមារ (១៩៨៩) (មាត្រា៣៩)។ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (UNCAT) (1984) (មាត្រា១៤)។ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (១៩៩៨) (មាត្រា៧៥)។ ក៏មានផងដែរនៅក្នុងលិខិតុបករណ៍តំបន់។ ឧទាហរណ៍ អនុសញ្ញាអឺរ៉ុបស្ដីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន (ECHR) (មាត្រា៥(៥), ១៣ និង ៤១)។ អនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស (ACHR) (១៩៦៩) (មាត្រា២៥, ៦៣(១) និង ៦៨) និងធម្មនុញ្ញអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ (ACHPR) (១៩៨១) (មាត្រា២១(១)។ សូមមើលផងដែរ, អនុសញ្ញាអន្តរជាតិស្ដីពីការការពារបុគ្គលទាំងឡាយពីការបាត់ខ្លួនដោយបង្ខំ (ICPPED), (២០០៦-- មិនទាន់ចូលជាធរមាននៅឡើយទេ។ នៅពេលកំពុងសរសេរអនុសញ្ញានេះមានហត្ថលេខាចំនួន៨៣ និងការផ្ដល់សច្ចាប័នចំនួន១៩ (មាត្រា២៤)។

[27] សូមមើល ឧទាហរណ៍, គណៈកម្មការសិទ្ធិមនុស្ស (HRC), យោបល់ទូទៅ (GC) លេខ 31 [80] Nature of the General Legal Obligation Imposed on States Parties to the Covenant 26/05/2004, (ឯកសារ អ.ស.ប CCPR/C/21/Rev.1/Add.13, ត្រង់កថាខណ្ឌ 15-17។ គណៈកម្មការអង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម (CAT), GC No. 2, ការអនុវត្តមាត្រា២ ដោយរដ្ឋភាគី, ឯកសារ អ.ស.ប CAT/C/GC/2/CRP. 1/Rev.4 (2007).) ត្រង់កថាខណ្ឌ 15។

00623049



២៣. កម្ពុជាមានកាតព្វកិច្ចផ្តល់សំណងដល់ជនរងគ្រោះដោយសារអំពើយង់ឃ្នង ដែលពួកខ្មែរក្រហមបានប្រព្រឹត្ត។ ព្រះរាជាណាចក្រកម្ពុជាគឺជាភាគីមួយក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួន ដែលភាគច្រើនចែងអំពីកាតព្វកិច្ចសម្រាប់រដ្ឋទាំងឡាយដែលជាភាគី ក្នុងការធានានូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពសម្រាប់ជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស[31]។

---

[28] សូមមើល ឧទាហរណ៍, IACHR, រឿងក្តី Velásquez-Rodriguez តទល់នឹង Honduras, កថាខណ្ឌ 174។ សូមមើលផងដែរ តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR), រឿងក្តី Papamichalopoulos តទល់នឹង Greece (មាត្រា 50), (បណ្តឹងលេខ 14556/89) សាលក្រម (ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៥) ត្រង់កថាខណ្ឌ៣៦។

[29] Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law, សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប លេខ 60/147 នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥។ សូមមើលផងដែរ សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច, ត្រូវបានអនុម័តដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 40/34 of 29 Nov. 1985; និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) (១៩៤៨), (មាត្រា៨)។

[30] សូមមើល តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ, រឿងក្តីទាក់ទងនឹងរោងចក្រនៅ Chorzów, Series A, No. 17, ចុះថ្ងៃទី១៣ កញ្ញា ឆ្នាំ១៩២៨ (អង្គសេចក្តី), ទំព័រ29, 47។ Series A, No. 9, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩២៧ (ទាមទារការការពារ), ទំព័រ 21; IACHR, រឿងក្តី Velázquez-Rodríguez តទល់នឹង Honduras, សាលក្រម ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨៩ (សំណងនិងតម្លៃ), កថាខណ្ឌ 25។

[31] ឧទាហរណ៍ មាត្រា២ (៣) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ “រដ្ឋភាគីនៃកាតិកាសញ្ញានេះសន្យា៖ (ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះជននោះមានសិទ្ធិឲ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។ (ខ) ធានាថា ជនណាដែលប្តឹងឲ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឲ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឲ្យខ្លួន ដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។ (គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តឲ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។” មាត្រា១៤ នៃអនុសញ្ញាអ.ស.ប ប្រឆាំងនឹងការធ្វើទារុណកម្មចែងថា “១. រដ្ឋភាគីត្រូវបានធានាក្នុងប្រព័ន្ធច្បាប់របស់ខ្លួនថា ជនរងគ្រោះពីអំពើទារុណកម្ម មានសិទ្ធិទទួលបានការជួសជុល និងសិទ្ធិបង្គាប់សំណងខូចខាតសមរម្យ និងគ្រប់គ្រាន់ រួមមានមធ្យោបាយស្តារនីតិសម្បទាឲ្យបានពេញលេញ តាមដែលអាចធ្វើទៅបានផង។ ក្នុងករណីជនរង

២៤. គោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ការរំលោភដ៏កម្រោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ[32] ("*គោលការណ៍មូលដ្ឋាននៃអង្គការសហប្រជាជាតិ*) ចែងថាជនរងគ្រោះមានសិទ្ធិស្នើសុំវិធានការសមស្រប និងប្រកបដោយប្រសិទ្ធភាព។

២៥. ទោះបីជាយ៉ាងដូច្នេះក្តី អង្គជំនុំជម្រះសាលាដំបូងមានភាពត្រឹមត្រូវត្រង់ថាខ្លួនគ្មានយុត្តាធិការបង្គាប់ឱ្យព្រះរាជាណាចក្រកម្ពុជា សងសំណងឡើយ។ ប៉ុន្តែបញ្ហានេះពុំបានរារាំង អ.ជ.ស.ដ មិនឱ្យចេញដីកាបង្គាប់ឱ្យសងសំណងប្រឆាំងនឹងជនជាប់ចោទឡើយ។ ក្នុងការសងសំណង គេអាចត្រូវការ**ជំនួយ**ពីសំណាក់រដ្ឋាភិបាល និងការគាំទ្រ**មិនមែនហិរញ្ញវត្ថុ** និង**ផ្នែករដ្ឋ**បាល ជាជាងការរួមវិភាគទានហិរញ្ញវត្ថុ។ ជំនួយប្រភេទនេះគឺជាភារកិច្ចទូទៅមួយរបស់រដ្ឋក្នុងការយកចិត្តទុកដាក់អំពីតម្រូវការរបស់ប្រជាជនដែលខ្លួនត្រូវបម្រើ។ ដូច្នេះ សំណងទាំងឡាយដែលត្រូវការជំនួយពីរដ្ឋ ដូចជាការអនុញ្ញាតឱ្យសាងសង់អគារនៅលើដីសាធារណៈ ឬការអនុញ្ញាតឱ្យដាក់ឈ្មោះអគារតាមឈ្មោះជនរងគ្រោះ។ល។ គឺជាសំណងដែលអាចទទួលយកបាន ដោយហេតុថាសំណងទាំងនេះពុំមែនជាទណ្ឌកម្មរបស់ព្រះរាជាណាចក្រកម្ពុជាឡើយ។ តាមលក្ខណៈរបស់វា សំណងផ្លូវចិត្តជាសមូហភាពភាគច្រើន អាចត្រូវបានសងក្រោមការជួយឧបត្ថម្ភគាំទ្រពីសំណាក់រដ្ឋាភិបាល។

២៦. លើសពីនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់នូវអង្គហេតុដែលថាទោះបីជនជាប់ចោទជាជនក្រីក្រ ហើយមានប្រភពហិរញ្ញវត្ថុមិនច្បាស់លាស់ក្តី ក៏ អ.ជ.ស.ដ ពុំត្រូវបានគេហាមឃាត់មិនឱ្យផ្តល់សំណងឡើយ។ វិធាន២៣(១១) ចែងថា "ការផ្តល់សំណងនេះត្រូវធ្វើឡើងប្រឆាំងនឹងទណ្ឌិត និងជាបន្ទុករបស់ទណ្ឌិត"។ ភាពក្រីក្ររបស់ជនជាប់ចោទពុំអាចមានការប៉ះពាល់ណាមួយដល់ការបង្គាប់ឱ្យសងសំណងឡើយ។ ជារឿងអាចកើតឡើងបានដែលថាជនជាប់ចោទអាចពុំមែនជាជនក្រីក្រទៅថ្ងៃមុខ។ ដូច្នេះ តុលាការត្រូវចេញដីកាបង្គាប់ឱ្យសងសំណង

---

គ្រោះស្លាប់ដោយអំពើទារុណកម្ម សិទ្ធិវ័ន្តនៃជនរងគ្រោះមានសិទ្ធិទទួលសំណង ២. គ្មានបទបញ្ញត្តិណាមួយក្នុងមាត្រានេះ ប៉ះពាល់ដល់សិទ្ធិណាមួយនៃជនរងគ្រោះ ឬជនផ្សេងទៀត ដើម្បីទទួលសំណងដែលអាចមានក្នុងច្បាប់ជាតិឡើយ។"

[32] សូមមើល យោងខាងលើ កំណត់សម្គាល់លេខ២៩។

ដោយពុំគិតថាជនជាប់ចោទមានស្ថានភាពហិរញ្ញវត្ថុយ៉ាងណា និងទទួលការកាត់ទោសយ៉ាងណា និងមានភាពក្រីក្រយ៉ាងណានោះទេ។

២៧. បន្ថែមពីលើនេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា យោងតាមវិធាន ២៣(១)(ខ) និង២៣(១១) ជនរងគ្រោះអាចទាមទារ "សំណងផ្លូវចិត្តជាសមូហភាព"។ យោងតាមវិធាន២៣(១២) សំណងទាំងនេះអាចធ្វើឡើងក្រោមរូបភាពដូចជា "ក) ការបង្គាប់ឱ្យបោះពុម្ពផ្សាយសាលក្រម ឬសាលដីកា នៅក្នុងសារព័ត៌មានសមស្របណាមួយ ដែលការចំណាយជាបន្ទុករបស់ទណ្ឌិត ខ) ការបង្គាប់ឱ្យផ្តល់មូលនិធិដល់សកម្មភាព ឬសេវាកម្មមិនរកប្រាក់ចំណេញណាមួយដែលមានគោលបំណងផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ ឬ គ) ទម្រង់ដទៃទៀតនៃសំណងដែលមានលក្ខណៈ សមរម្យ និងប្រហាក់ប្រហែល"។

២៨. ដូច្នេះ អ.វ.ត.ក មានសិទ្ធិអំណាចចេញដីកាបង្គាប់ឱ្យសងសំណង ពិសេសក្នុងវង្វង់វិធាន២៣(១២)។ វិធាន២៣(១២)(គ) បើកចំហឱ្យមានការផ្តល់សំណងតាមរូបភាពផ្សេងៗជាច្រើន។

## VI. **ឧទ្ធរណ៍**

### **ក. មូលដ្ឋានរួមទី១ នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងសំណើទាំងអស់ដែលត្រូវបានបដិសេធ**

២៩. អង្គជំនុំជម្រះសាលាដំបូងបានលើកយកសំណើសុំទាមទារសំណងទាំង៣៦ របស់ដើមបណ្តឹងរដ្ឋប្បវេណី[33] មកវិភាគត្រឹមតែក្នុងចំនួន៩ កថាខណ្ឌប៉ុណ្ណោះ[34]។ ក្នុងការវិភាគនេះ អង្គជំនុំជម្រះសាលាដំបូងសង្ខេបបំព្រួញសំណើទាំងអស់នោះដោយពុំបញ្ជាក់ឱ្យបានច្បាស់ថា តើខ្លួនបានពិនិត្យទៅលើសំណុំណាមួយត្រង់កថាខណ្ឌណាមួយឡើយ ហើយខ្លួនពុំបានភ្ជាប់ការវិភាគនោះទៅនឹងសំណើនីមួយៗឡើយ។

៣០. ការផ្តល់សំអាងហេតុពុំបានពេញលេញគ្រប់គ្រាន់ពីសំណាក់អង្គជំនុំជម្រះ ជាការរំលោភគោលការណ៍ច្បាប់ជាមូលដ្ឋានដែលតម្រូវឱ្យមានសំអាងហេតុត្រឹមត្រូវចំពោះការសម្រេចណាមួយ។ មិនខុសគ្នា

---

[33] សំណើលេខទី៨ ក្នុងនាមមេធាវីក្រុម១, សំណើទី៩ក្នុងនាមមេធាវីក្រុម២ និងសំណើទី១៤ ក្នុងនាមមេធាវីក្រុម៣។

[34] សាលក្រម កថាខណ្ឌ៦៦៧-៦៧៤។

ប៉ុន្មាន ការផ្តល់សំអាងហេតុពុំបានគ្រប់គ្រាន់ និង/ឬ ពេញលេញ ពុំផ្តល់ឱ្យអង្គជំនុំជម្រះតុលាការកំពូលនូវព័ត៌មានអតិបរមាចាំបាច់សម្រាប់ពិនិត្យមើលឡើងវិញ នូវសេចក្តីសម្រេចឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាពឡើយ[35]។

## ១. សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុជាគោលការណ៍ច្បាប់ជាមូលដ្ឋាន

៣១. ដោយហេតុថាវិធានផ្ទៃក្នុងបច្ចុប្បន្នខ្វះចន្លោះស្តីពីលក្ខខណ្ឌតម្រូវនៃសេចក្តីសម្រេច ដោយមានសំអាងហេតុច្បាប់ អ.វ.ត.ក អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកការណែនាំពីវិធាននីតិវិធីអន្តរជាតិ[36]។ សិទ្ធិទទួលបានការសម្រេចដោយត្រឹមត្រូវទៅលើបញ្ហាបានទទួលការគាំពារតាមមាត្រា១៤.១ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")[37]។ ការខកខានរបស់ អ.ជ.ស.ជ ក្នុងការពុំបានចេញសេចក្តីសម្រេចដោយមានសំអាងហេតុ ទៅលើសំណើនីមួយៗគឺជាការបដិសេធយ៉ាងច្បាស់ក្រឡែត នូវសិទ្ធិក្នុងការទទួលបានការសម្រេចទៅលើបញ្ហាដោយត្រឹមត្រូវ។ ពិសេស ចំណុចនេះរាប់ទាំងសិទ្ធិក្នុងការដឹងច្បាស់លាស់អំពីមូលហេតុក្នុងការបដិសេធណាមួយ និងសិទ្ធិចូលរួមស្តាប់សវនាការឱ្យបានត្រឹមត្រូវ ដោយហេតុថាដើមបណ្តឹងរដ្ឋប្បវេណីពុំអាចឆ្លើយតបទៅនឹងការជំទាស់ដោយពុំបានដឹងអំពីមូលហេតុនោះទេ។

៣២. មាត្រា៤៥(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ("អនុសញ្ញា ECHR") ចែងថា "ត្រូវមានសំអាងហេតុ ចំពោះសាលក្រម ព្រមទាំងសេចក្តីសម្រេចទទួលស្គាល់ ឬបដិសេធសំណើនានា"។ មាត្រានេះចែងអំពីគោលការណ៍ច្បាប់ជាមូលដ្ឋានមួយក្នុងចំណោមគោលការណ៍នានា។ ដោយយោងទៅ

---

[35] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០, ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D353/2/3, កថាខណ្ឌ២៣, (*បន្ទាប់ពីនេះយោងដោយ៖* សាលដីកាលើបណ្តឹងឧទ្ធរណ៍មេធាវីការពារក្តី អៀង ធីរិទ្ធ)។

[36] សូមមើល ច្បាប់ អ.វ.ត.ក មាត្រា២០ថ្មី, ២៣ថ្មី និង៣៣ថ្មី។

[37] មាត្រា១៤ (១) នៃ ICCPR ចែងថា៖ "ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី។"

លើមាត្រា៦(១) នៃអនុសញ្ញានេះ ក្នុងសេចក្តីសម្រេចមួយចំនួន តុលាការសិទ្ធិមនុស្សអឺរ៉ុបក៏បានបញ្ជាក់ថា "យោងតាមច្បាប់យុត្តិសាស្ត្រដ៏រឹងមាំរបស់ខ្លួន សាលក្រមទាំងឡាយរបស់តុលាការ និងសាលាក្តីគួរតែបញ្ជាក់ឱ្យបានគ្រប់គ្រាន់នូវសំអាងហេតុ ដែលខ្លួនយកធ្វើជាមូលដ្ឋាន"[38] ដោយហេតុថា "ការផ្តល់សំអាងហេតុមានភាពចាំបាច់ដល់គុណតម្លៃនៃយុត្តិធម៌ និងផ្តល់ការគាំពារប្រឆាំងនឹងការធ្វើអ្វីតាមតែទំនើងចិត្ត"[39]។ សាលាក្តីអន្តរជាតិ(តួបនីយកម្ម) ផ្សេងៗ រួមទាំង អ.វ.ត.ក ផង ប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវលក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយនេះ[40]។

---

[38] តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR), រឿងក្តី *Taxquet តទល់នឹង Belgium*, បណ្តឹងលេខ 926/05, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ កថាខណ្ឌ៤០។

[39] *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ៤៣។

[40] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍មេធាវីការពារក្តី អៀង ធីរិទ្ធ ត្រង់កថាខណ្ឌ២៩, ដោយបានដកស្រង់នូវសាលាដីការបស់តុលាការឧទ្ធរណ៍ ICTY ប៉ុន្តែពុំមានព័ត៌មានបន្ថែមណាមួយដែលសាលដីកាលើកយកមកយោងឡើយ។ ស្រដៀងគ្នានេះ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY បានកំណត់ថាសិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំមួយនៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយមានតែតាមមូលដ្ឋាននៃសេចក្តីសម្រេចដែលមានសំអាងហេតុប៉ុណ្ណោះ ទើបគេអាចពិនិត្យមើលសេចក្តីសម្រេចនោះឡើយវិញបានត្រឹមត្រូវ។ (សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Momir Nikolic, សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីការកាត់ទោស, ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០០៦ សំណុំរឿងលេខ IT-02-60/1-A, កថាខណ្ឌ96។ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Dragoljub Kunarac និងអ្នកផ្សេងទៀត, សាលក្រម, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២, សំណុំរឿងលេខ IT-96-23&23/1-A, កថាខណ្ឌ 41)។ ក្នុងកថាខណ្ឌ 11 នៃ "សេចក្តីសម្រេចរបស់ខ្លួនស្តីពីបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អីពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានអនុញ្ញាតឱ្យមានការដោះលែងបណ្តោះអាសន្ន Nebojsa Pavkovic" នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្នុងរឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milutinovic និងអ្នកផ្សេងទៀត (សំណុំរឿងលេខ IT-05-87-AR65.1), អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានលើកឡើងថា "ក្នុងកម្រិតអតិបរមា អង្គជំនុំជម្រះសាលាដំបូងត្រូវផ្តល់នូវសំអាងហេតុដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួន ពាក់ព័ន្ធនឹងការពិចារណាអំពីអង្គសេចក្តីសំខាន់ៗ ពាក់ព័ន្ធនឹងសេចក្តីសម្រេចណាមួយរបស់ខ្លួន"។ សូមមើលផងដែរ៖ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Lubanga សំណុំរឿងលេខ ICC-01/04-01/06-774 OA6, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Thomas Lubanga Dyiloប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះI , សេចក្តីសម្រេចលើកទី២ស្តីពីសំណើសុំរបស់រដ្ឋអាជ្ញា និងសំណើដែលបានកែប្រែសុំឱ្យមានការកោសលុប តាមវិធាន៨១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ៣០៖ "សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ គឺជាធាតុផ្សំមួយនៃសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមានតែតាម

៣៣. អ.ប.ជ នៃ អ.វ.ត.ក បានយកលក្ខខណ្ឌតម្រូវនេះតាមតុលាការ ECHR[41] ហើយអង្គជំនុំជម្រះតុលាការកំពូលគួរបន្តយកលក្ខខណ្ឌតម្រូវនេះ មកអនុវត្តក្នុងសំណុំរឿងនេះ។ ក្នុងសេចក្តីសម្រេចជាឯកច្ឆន្ទមួយ អ.ប.ជ បានសម្រេចថាទោះបីច្បាប់យុត្តិសាស្ត្ររបស់តុលាការ ECHR ខាងលើពាក់ព័ន្ធនឹងការសម្រេចជាស្ថាពរទៅលើពិរុទ្ធភាពក្តី ក៏ "វាមានសារៈសំខាន់ពាក់ព័ន្ធនឹងបរិបទមុនការជំនុំជម្រះនៅអ.វ.ត.ក"ដែរ[42]។ ត្រង់បញ្ហានេះ ម្ចាស់បណ្តឹងសាទុក្ខបានប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចមួយរបស់ ស.ច.ស ដែលបានបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយហេតុថាក្នុងដីកាសម្រេចនោះពុំមានសំអាងហេតុត្រឹមត្រូវឡើយ[43]។

៣៤. ការខកខានពុំបានផ្តល់សំអាងហេតុលម្អិតគ្រប់គ្រាន់ ក្នុងការបដិសេធទៅនឹងសំណើសុំទាមទារសំណង គឺជាការរំលោភសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ។ តាមរយៈការផ្តល់សិទ្ធិប្តឹងសាទុក្ខ សេចក្តីសម្រេចស្តីពីការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក ទទួលស្គាល់នូវសារៈសំខាន់នៃសិទ្ធិតាមនីតិវិធីមួយនេះ។ ដូច្នេះ សេចក្តីសម្រេចត្រូវមានការបញ្ជាក់ឱ្យបានលម្អិតគ្រប់គ្រាន់ ដើម្បីធ្វើឱ្យមានសំណើចុងក្រោយនេះ និងជាសំណើប្រកបទៅដោយអត្ថន័យ។

៣៥. ដូចដែលតុលាការ ECHR បានសម្រេចក្នុងសំណុំរឿង *Taxquet* ថា "វិសាលភាពដែលភារកិច្ចក្នុងការផ្តល់សំអាងហេតុនេះត្រូវយកមកអនុវត្ត អាចខុសប្លែកពីគ្នាទៅតាមលក្ខណៈនៃសេចក្តីសម្រេចនោះ ហើយត្រូវកំណត់ទៅតាមកាលៈទេសៈនៃសំណុំរឿង (...)"[44]។ ក្នុងករណីមានការ

---

មូលដ្ឋាននៃសេចក្តីសម្រេចដែលមានសំអាងហេតុប៉ុណ្ណោះ ដែលនឹងធ្វើឱ្យមានការពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេច បានត្រឹមត្រូវ។

[41] សាលដីកាលើបណ្តឹងឧទ្ធរណ៍មេធាវីការពារក្តី អៀង ធីរិទ្ធ, កថាខណ្ឌ២៨។

[42] *ដូចជើងទំព័រខាងលើ*។

[43] *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ៣០ (ប្រៀបធៀប កថាខណ្ឌ៣១, អ.ប.ជ បានកត់សម្គាល់ថា កំហុសអង្គច្បាប់របស់ ស.ច.ស នឹងតម្រូវឱ្យ អ.ប.ជ ច្រានចោលដីកាសម្រេចរបស់ ស.ច.ស ប៉ុន្តែមានសំអាងហេតុដែលមានសុពលភាពផ្សេងៗទៀត ដែលគាំទ្រដីកាសម្រេចរបស់ ស.ច.ស)។

[44] យោងខាងលើ កំណត់សម្គាល់លេខ ៤២ កថាខណ្ឌ៤០។

បដិសេធសំណើសុំទាមទារសំណងក្នុងចំនួនភាគច្រើន ដើមបណ្តឹងរដ្ឋប្បវេណីត្រូវការចង់ដឹងសំអាងហេតុលម្អិត ទៅតាមទំហំនៃសំណងសម្រាប់ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សដ៏កម្រោល។ លើសពីនេះ លើកលែងតែមានភាពច្បាស់លាស់ថាអាចមានសំណុំរឿងបន្ថែមទៀតនៅ អ.វ.ត.ក ក្នុងការអនុវត្តជាក់ស្តែង ជនរងគ្រោះភាគច្រើនមានឱកាសតែម្តងប៉ុណ្ណោះ ដើម្បីទាមទារសំណងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ ប្រការសំខាន់ ប្រសិនបើគ្មានសំអាងហេតុត្រឹមត្រូវទេនោះ មូលដ្ឋានសម្រាប់បណ្តឹងសាទុក្ខមួយប្រកបដោយអត្ថន័យក៏មិនអាចមានដែរ។

៣៦. តាមហេតុផលអស់ទាំងនេះ ការខកខានពុំបានចេញសេចក្តីសម្រេចណាមួយដែលមានសំអាងហេតុត្រឹមត្រូវ ក៏ជាការរំលោភផងដែរទៅលើគោលការណ៍ទី៤ នៃសេចក្តីប្រកាសស្តីពីគោលការណ៍សាធារណៈនៃយុត្តិធម៌សម្រាប់ជនរងគ្រោះ និងការប្រើអំណាចបំពាន ដែលចែងថា "ជនរងគ្រោះគួរត្រូវបានប្រព្រឹត្តមកលើដោយក្តីសន្តោសប្រណី និងការគោរពដល់សេចក្តីថ្លៃថ្នូររបស់ពួកគាត់"[45]។ ការបដិសេធណាមួយដោយគ្មានសំអាងហេតុត្រឹមត្រូវ ពុំត្រឹមជាការដកហូតសិទ្ធិតាមនីតិវិធីជាមូលដ្ឋានឡើយ ប៉ុន្តែថែមទាំងជាការដកហូតសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះម្តងទៀត ដែលម្តងនេះធ្វើឡើងដោយស្ថាប័នតុលាការអន្តរជាតិ (តួបនីយកម្ម)។

## ២. វិសាលភាពនៃការផ្តល់សំអាងហេតុ

៣៧. វិធាន២១ នៃវិធានផ្ទៃក្នុងចែងថា៖

> *"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ ប្រយោជន៍របស់ (...) ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ...ក្នុង*

---

[45] សេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះ នៃឧក្រិដ្ឋកម្ម និងការរំលោភអំណាច, ត្រូវបានអនុម័តដោយ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ អ.ស.ប លេខ 40/34, ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥, គោលការណ៍ទី4។

*បរិបទនេះ៖ ...(គ) អ.វ.ត.ក ត្រូវធានាថាជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការ ពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី...”*

៣៨. ក្នុងការខកខានពុំបានផ្តល់សំអាងហេតុលម្អិតគ្រប់គ្រាន់ អ.ជ.ស.ដ បានខកខានក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមវិធាន ២១ “ធានាអំពីសច្ចភាពផ្លូវច្បាប់ និងតម្លាភាព”។ ខ្លួនថែមទាំងបានរំលោភវិធាន ២១(គ) នៃវិធានផ្ទៃក្នុង តាមរយៈការខកខានពុំបានជូនព័ត៌មានដល់ជនរងគ្រោះអំពីមូលដ្ឋាននៃសេចក្តីសម្រេចទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍ជនរងគ្រោះ និងការខកខានពុំបានគោរពសិទ្ធជនរងគ្រោះ ក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី។

៣៩. យុត្តិសាស្ត្រអន្តរជាតិទទួលស្គាល់ហេតុផលចម្បងចំនួន២ ដែលជាមូលដ្ឋាននៃសិទ្ធិក្នុងការទទួលបានសេចក្តីសម្រេចដោយមានសំអាងហេតុ[46]។ ទីមួយ ជនដែលពាក់ព័ន្ធត្រូវមានលទ្ធភាពដឹងហេតុផលនៃការជំទាស់ដែលខ្លួនចង់ប្តឹងសាទុក្ខ។ ទីពីរ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ពុំអាចពិនិត្យមើលសេចក្តីសម្រេចឱ្យបានត្រឹមត្រូវ និងស៊ីជម្រៅបានឡើយ ប្រសិនបើគ្មានសំអាងហេតុ។

៤០. តុលាការអន្តរជាតិលែងកំណត់វិសាលភាពពិតប្រាកដ នៃការផ្តល់សំអាងហេតុដែលចាំបាច់ទៀតហើយ ដោយផ្ទុយទៅវិញ តុលាការនេះបានសម្រេចថាវិសាលភាពនៃសំអាងហេតុ ត្រូវលើកយកមកពិចារណាម្តងមួយករណី អាស្រ័យទៅតាមកាលៈទេសៈ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ (“ICC”) បានគូសបញ្ជាក់ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Lubanga ថា៖*

> *“សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលបានបង្គាប់ឱ្យពុំមានការបង្ហើបណាមួយដល់មេធាវីការពារក្តីនូវអត្តសញ្ញាណសាក្សីរបស់រដ្ឋអាជ្ញា ត្រូវមានសំអាងហេតុគាំទ្រគ្រប់គ្រាន់។ វិសាលភាពនៃការផ្តល់សំអាងហេតុនឹងអាស្រ័យទៅតាមកាលៈទេសៈនៃរឿងក្តី ប៉ុន្តែជាការចាំបាច់ដែលការផ្តល់សំអាងហេតុ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់អំពីមូលដ្ឋាននៃសេចក្តីសម្រេច។ ការផ្តល់សំអាងហេតុនេះនឹងពុំចាំបាច់តម្រូវឱ្យមានការលើកឡើងម្តងទៀតនូវ*

---

[46] សូមមើល ឧទាហរណ៍ ក្នុងយោងខាងលើ កំណត់សម្គាល់លេខ៤០។

*កត្តានីមួយៗ ដែលអង្គបុរេជំនុំជម្រះត្រូវរៀបរាប់ ប៉ុន្តែការផ្តល់សំអាងហេតុនេះត្រូវបង្ហាញថា អង្គហេតុណាមួយដែលខ្លួនបានយល់ឃើញថាពាក់ព័ន្ធទៅដល់សេចក្តីសន្និដ្ឋាន*"[47] ។

៤១. យោងតាមសំណុំរឿង *Lubanga* យ៉ាងហោចណាស់ សំអាងហេតុត្រូវមានការបញ្ជាក់ឱ្យបានច្បាស់អំពីអង្គហេតុពាក់ព័ន្ធនានាដែលនាំទៅដល់ការសន្និដ្ឋាន។ ការលើកឡើងច្រំដែល និងមូលដ្ឋានទូលំទូលាយ សម្រាប់ការជំទាស់ ឬការជំទាស់ *ជាទ្រង់ទ្រាយធំ* ទៅលើសំណើសុំជាច្រើនតាមមូលហេតុទូលំទូលាយ និងពុំច្បាស់លាស់ គឺពុំទាន់គ្រប់គ្រាន់ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវដែលទាមទារឱ្យបង្ហាញសំអាងហេតុគ្រប់គ្រាន់ទៅលើសេចក្តីសម្រេចឡើយ។ សេចក្តីសម្រេចដែលមានសំអាងហេតុត្រឹមត្រូវ យ៉ាងហោចណាស់ក៏គួរបានយោងទៅលើសំណើសុំទាមទារសំណងនីមួយៗ និងបានពិភាក្សាអំពីអង្គហេតុទាំងនេះក្នុងការអនុវត្តវិធានផ្ទៃក្នុង[48] និងយុត្តិសាស្ត្រអន្តរជាតិស្តីពីសំណង។

៤២. ក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ[49] អ.ប.ជ ពុំបានឯកភាពតាមការយោងរបស់ ស.ច.ស ទៅលើ "ព័ត៌មានដែលមានរួចហើយនៅក្នុងសំណុំរឿង" ឡើយ និងបានសម្រេចថាត្រូវផ្តល់ "ក្នុងកម្រិតអប្បបរមា នូវព័ត៌មានគំរូទាំងនេះ រាប់ទាំងលេខឯកសារពាក់ព័ន្ធក្នុងករណីសមស្រប"។

៤៣. តាមរយៈការយកបទដ្ឋានបែបនេះមកអនុវត្តចំពោះសាលក្រម ដែលត្រូវបានជំទាស់ត្រង់ផ្នែកស្តីពីសំណង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា អ.ជ.ស.ដ ពុំបានវិភាគទៅលើសំណើណាមួយឱ្យបានជាក់លាក់ឡើយទាំងនៅក្នុងជើងទំព័រ និងក្នុងអត្ថបទ។

---

[47] សូមមើល យោងខាងលើ កំណត់សម្គាល់លេខ៤៤, *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo*, សាលក្រម, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦, កថាខណ្ឌ៣០។ លក្ខន្តិកៈ និងវិធាននៃនីតិវិធី បញ្ជាក់ជាច្រើនកន្លែងអំពីសារៈសំខាន់នៃសំអាងហេតុគ្រប់គ្រាន់ ជាក់ស្តែងក្នុងបរិបទនៃបញ្ហាភស្តុតាង វិធាន៦៤(២) នៃវិធាននីតិវិធី និងភស្តុតាង ដែលតម្រូវឱ្យអង្គជំនុំជម្រះ "ផ្តល់សំអាងហេតុចំពោះការសម្រេចណាមួយដែលខ្លួនធ្វើ"។

[48] វិធាន២៣ (១) (ខ) និង ២៣ (១១) និង (១២)។

[49] យោងខាងលើ កំណត់សម្គាល់លេខ៣៩។

ចំណុចនេះបានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីគ្មានលទ្ធភាពភ្ជាប់ទំនាក់ទំនងនៃ "ការវិភាគ" នោះទៅនឹងសំណើនីមួយៗ។

៤៤. គោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌តម្រូវថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលព័ត៌មានអំពីសំអាងហេតុនៃការជំទាស់ទៅនឹងសំណើទាមទារសំណងរបស់ពួកគាត់ ហើយត្រូវលើកយកសំណើនីមួយៗមកធ្វើការពិចារណាឱ្យបានល្អិតល្អន់ ហើយការវិភាគនោះត្រូវបង្ហាញឱ្យបានច្បាស់លាស់ថា តើជាការវិភាគលើសំណើណាមួយ ត្រង់កថាខណ្ឌណាមួយ។ អ.ជ.ស.ជ បានរំលោភលើគោលការណ៍នេះ។

## ខ. សំណើទី១÷ ការចងក្រង និងការផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោស

៤៥. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមាន "ការចងក្រង និងការផ្សព្វផ្សាយសេចក្តីថ្លែងសុំអភ័យទោសរបស់ ឌុច នៅអំឡុងពេលនៃសវនាការ ដែលបានទទួលស្គាល់ការឈឺចាប់ និងទុក្ខវេទនារបស់ជនរងគ្រោះ រួមនឹងយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសូមអភ័យទោសទាំងអស់នេះ"[50]។ អង្គជំនុំជម្រះបានទទួលយកសំណើនេះមួយផ្នែក ហើយបានបដិសេធការទាមទារឱ្យ ដាក់បញ្ចូលយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសុំអភ័យទោសទាំងអស់នេះ។

៤៦. ចាប់តាំងពីពេលចាប់ផ្តើមនៃកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាពួកគាត់មានការមន្ទិលសង្ស័យថា តើការសុំអភ័យទោសរបស់ជនជាប់ចោទជាការពិតស្មោះត្រង់ដែរឬទេ។ គោលបំណងនៃសំណើនេះ គឺដើម្បីសម្តែងយោបល់ទៅលើភាពមន្ទិលសង្ស័យទាំងអស់នេះ និងដើម្បីបង្ហាញនូវការឆ្លើយឆ្លងគ្នារវាងការសុំអភ័យទោសរបស់ជនជាប់ចោទ និងការយល់ឃើញរបស់ដើម្បីបណ្តឹងរដ្ឋប្បវេណីទៅលើការសុំអភ័យទោសទាំងអស់នោះ។ បន្ទាប់ពីមេធាវីការពារក្តីជាតិបានស្នើសុំឱ្យមានការលើកលែងបទចោទប្រឆាំងនឹងជនជាប់ចោទ និងសុំឱ្យមានការដោះលែងជនជាប់ចោទនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលជាថ្ងៃចុងក្រោយនៃសេចក្តីសន្និដ្ឋានបញ្ចប់

---

[50] សារណារួម, កថាខណ្ឌ៤៥។

កិច្ចពិភាក្សាដេញដោល សំណើសុំទាមទារសំណងនេះលែងមានអត្ថន័យខ្លឹមសារអ្វីទៀតហើយ ហើយកាន់តែគ្មានអត្ថន័យខ្លឹមសារថែមទៀត នៅពេលគ្មានសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើការសូមអភ័យទោសទាំងនេះក្នុងអំឡុងពេលនៃសវនាការ។

**មូលដ្ឋានទីពីរនៃបណ្តឹងសាទុក្ខ៖ ការរំលោភវិធាន២១(ក) និង(គ)**

៤៧. វិធាន២១(១)(ក) និង(គ) នៃវិធានផ្ទៃក្នុង ចែងថា៖

*"ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ ប្រយោជន៍របស់ (...) ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព...*

*(ក) ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី ទាំងឡាយ..."*

*(ខ) (...)*

*(គ) អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថាជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការ ពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"* ។

៤៨. អង្គជំនុំជម្រះបានផ្អែកការបដិសេធរបស់ខ្លួនទៅលើ "មូលដ្ឋាន" ដែលថាយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ

(i) ខុសពីការសូមអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ និង

(ii) ខ្លឹមសារនៃយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីពុំទាន់បានបញ្ជាក់ច្បាស់លាស់។

៤៩. ផ្នែកទី១ ងាយស្រួលយល់ និងមានភាពសមហេតុផល និងវាជាការពិតឬយដែលថាបតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការសុំអភ័យទោសនោះ ខុសគ្នាពីការសុំអភ័យទោស។ ការដែលថាយោបល់សាក្សីមានភាពខុសគ្នា ពុំមែនជាសំអាងហេតុឡើយ។

៥០. ផ្នែកទី២ គឺមិនត្រឹមត្រូវទេ ហើយភាពមិនត្រឹមត្រូវនេះស្តែងឡើងយ៉ាងច្បាស់ នៅពេលមានការប្រៀបធៀបសំណើទាំង២នេះ។ ភាពជាក់លាក់មានកម្រិតដូចគ្នា។ សំណើសុំចងក្រងពាក្យសម្តីសុំអភ័យទោសរបស់ជនជាប់ចោទ ក្នុងអំឡុងពេលនៃសវនាការពុំមានបញ្ជាក់អ្វីលើសពីនេះទៀតឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី អ.ជ.ស.ដ បានទទួលយកសំណើនេះ។

៥១. ដូចគ្នានេះ សំណើសុំដាក់បញ្ចូលយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី **ទៅលើការសុំអភ័យទោសទាំងអស់នេះ** គឺពុំមានបញ្ជាក់អ្វីលើសពីនេះទៀតឡើយ ហើយសំណើនេះដូចគ្នាបេះបិទទៅនឹងសំណើសុំឱ្យមានការចងក្រងពាក្យសម្តីសុំអភ័យទោសរបស់ជនជាប់ចោទ។

៥២. ដូច្នេះ អ.ជ.ស.ដ ប្រព្រឹត្តផ្ទុយនឹងខ្លួនឯង នៅពេលខ្លួនទទួលយកសំណើដែលពុំមានភាពជាក់លាក់ ប៉ុន្តែ បែរជាបដិសេធសំណើដែលមានកម្រិតនៃភាពជាក់លាក់ដូចគ្នា ក្នុងសំណើសុំដាក់បញ្ចូលយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅលើការសូមអភ័យទោសទាំងនោះទៅវិញ។ សំអាងហេតុដែលផ្ទុយគ្នាគឺជាសំអាងហេតុមិនគ្រប់គ្រាន់អាចយកជាការបាន។

៥៣. ដូច្នេះតាមរយៈការមិនអើពើ និងការផ្អែកការជំទាស់លើមូលដ្ឋានខាងលើ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់ ដោយការខកខានពុំបានធ្វើសេចក្តីសម្រេចដោយមានសំអាងហេតុ និងបានរំលោភភារកិច្ចក្នុងការធានាថាសិទ្ធិជនរងគ្រោះត្រូវបានគោរព និងការពារក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ដូចមានចែងក្នុងវិធាន២១(១) (ក) និង(គ) ដើម្បីធានានូវសច្ចភាពតាមផ្លូវច្បាប់។

## គ. សំណើទី២: ការសរសេរលិខិតជាចំហរទៅកាន់រដ្ឋាភិបាលស្នើសូមការអភ័យទោសជាផ្លូវរដ្ឋ

៥៤. ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឱ្យ អ.ជ.ស.ដ បង្គាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឱ្យសរសេរលិខិតចំហរមួយតាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណីទៅរាជរដ្ឋាភិបាលកម្ពុជា ដោយស្នើសុំការអភ័យទោសជាផ្លូវការមួយ ប្រកបដោយភាពស្មោះត្រង់ មឺងម៉ាត់[51]។ អ.ជ.ស.ដ ពុំបានពិនិត្យទៅលើសំណើនេះ សូម្បីតែបន្តិចសោះឡើយ។

[51] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ៩-១៥។

## មូលដ្ឋានទី៣ នៃបណ្តឹងឧទ្ធរណ៍៖ ការរំលោភវិធាន១០០(១)

៥៥. វិធាន១០០(១) ចែងថាអង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ ដូច្នេះ តាមរយៈការពុំបានសម្រេចទៅលើសំណើនេះ អ.ជ.ស.ដ បានរំលោភវិធាន១០០(១)នេះ។

៥៦. ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងពុំបានធ្វើការយោងណាមួយរវាង "ការវិភាគ" និង សំណើទាំងនោះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមសន្មតថា អង្គជំនុំជម្រះសាលាដំបូងមានបំណងចង់ដាក់បញ្ចូលសំណើនេះនៅក្រោម "សំណើសុំវិធានការពីសំណាក់រដ្ឋាភិបាលកម្ពុជា"[52]។ អង្គជំនុំជម្រះបានបដិសេធសំណើសុំប្រភេទនេះ ដោយសំអាងថា សំណើទាំងនេះពុំស្ថិតក្នុងយុត្តាធិការ ហើយសេចក្តីថ្លែងសុំអភ័យទោសជាផ្លូវការស្ថិតនៅក្នុងបុព្វសិទ្ធិរដ្ឋាភិបាលជាតិដែល អ.វ.ត.ក គ្មានសមត្ថកិច្ចក្នុងការចាប់បង្ខំ[53]។

៥៧. ប្រសិនបើការពិតអង្គជំនុំជម្រះមានបំណងចង់ដាក់បញ្ចូលសំណើនេះក្រោម "សំណើសុំវិធានការពីសំណាក់រដ្ឋាភិបាលកម្ពុជា" មែន អង្គជំនុំជម្រះសាលាដំបូងពិតជាបានយល់ខុសទាំងស្រុងនូវអត្ថន័យរបស់សំណើ ដែលមានលក្ខណៈច្បាស់លាស់ និងងាយយល់ជាក់ជាមិនខាន។ សំណើនោះគឺការសរសេរលិខិតទៅកាន់រដ្ឋាភិបាល មិនមានអ្វីឲ្យហួសពីនេះទៀតឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីពុំបានស្នើសុំវិធានការពីសំណាក់រដ្ឋាភិបាលឡើយ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យ អ.ជ.ស.ដ បង្គាប់ឲ្យជនជាប់ចោទសរសេរលិខិតមួយទៅរដ្ឋាភិបាល។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការភ្ញាក់ផ្អើល ដោយហេតុថាអត្ថន័យដ៏ច្បាស់លាស់និងងាយយល់នៃសំណើនោះ អាចត្រូវបានអង្គជំនុំជម្រះសាលាដំបូងយល់ខុសថាជាសំណើសុំវិធានការពីសំណាក់រដ្ឋាភិបាលទៅវិញ។

៥៨. ដូច្នេះ អ.ជ.ស.ដ បានប្រព្រឹត្តកំហុសឆ្គង នៅពេលខ្លួនបានចាត់ទុកតាមការសន្មតថា សំណើនេះជា "សំណើសុំវិធានការពីសំណាក់រដ្ឋាភិបាលកម្ពុជា"។ អង្គជំនុំជម្រះពិតជាមានសមត្ថកិច្ចបង្គាប់ឲ្យ

---

[52] សាលក្រម កថាខណ្ឌ៦៧១។

[53] ដូចជើងទំព័រខាងលើ។

00623062



កាំង ហ្គេកអ៊ាវ ហៅ ឌុច សរសេរលិខិតមួយទៅរដ្ឋាភិបាល ប៉ុន្តែ អង្គជំនុំជម្រះ(១) ពុំបានចេញសេចក្តីសម្រេចណាមួយពាក់ព័ន្ធនឹងសំណើនេះឡើយ ដែលនេះគឺជាការរំលោភវិធាន១០០(១)។

### មូលដ្ឋានទី៤ នៃបណ្តឹងឧទ្ធរណ៍៖ កំហុសអង្គហេតុ

៥៩. តាមរយៈការពុំមានការសម្រេចណាមួយទាល់តែសោះពាក់ព័ន្ធនឹងសំណើនេះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គហេតុដែលនាំឱ្យមានភាពមិនយុត្តិធម៌។

៦០. ស្រដៀងគ្នានេះ ប្រសិនបើ អ.ជ.ស.ដ បានចាត់ទុកសំណើនេះជាសំណើមួយដែលស្នើសុំ “វិធានការពីសំណាក់រដ្ឋាភិបាល” នោះ អ.ជ.ស.ដ ពិតជាពុំបានអើពើ ឬយល់ច្រឡំនូវអត្ថន័យដ៏ច្បាស់លាស់នៃសំណើនេះយ៉ាងពិតប្រាកដ។ ការយល់ខុសដ៏ច្បាស់ក្រឡែតទៅលើសំណើនេះរាប់ថាជាកំហុសអង្គហេតុមួយដែលបាននាំឱ្យមានភាពមិនយុត្តិធម៌។

៦១. សរុបសេចក្តី អង្គជំនុំជម្រះសាលាដំបូងពុំបានសម្រេចលើសំណើនេះទាល់តែសោះ ឬពុំបានអើពើនូវអត្ថន័យដ៏ច្បាស់លាស់នៃសំណើនេះ និងបានប្រព្រឹត្តកំហុសអង្គហេតុ។

### ឃ. សំណើទី៣៖ ការកសាងបូជនីយដ្ឋាននៅមន្ទីរ ស-២១ និងជើងឯក និង សំណើទី៤៖ ការប្រែក្លាយព្រៃស ឱ្យទៅជាបូជនីយដ្ឋាន

៦២. ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការកសាងបូជនីយដ្ឋាន ក្នុងបរិវេណសារមន្ទីរទួលស្លែង និងនៅខាងឆ្វេង និងស្តាំដៃនៃចេតិយនៅជើងឯក។ បូជនីយដ្ឋានទាំងនោះគួរមានឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលជាអ្នកនៅរស់រានមានជីវិតផ្ទាល់ និងឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានសាច់ញាតិស្លាប់ ឬត្រូវបានសម្លាប់នៅមន្ទីរ ស-២១ និង/ឬ ជើងឯក ឆ្លាក់ជាអក្សរពណ៌ខ្មៅនៅលើផ្ទាំងថ្មម៉ាបពណ៌ស រួមបញ្ចូលទាំងថ្ងៃចូលមន្ទីរ ស-២១, ថ្ងៃស្លាប់ និងហេតុផលនៃការស្លាប់ និង/ឬទីកន្លែងនៃការស្លាប់។ ជាមួយគ្នានេះ គេក៏គួរបញ្ចូលព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងអត្តចរិត និងជីវិតរបស់ជនរងគ្រោះផងដែរ។ អត្ថបទដែលសរសេរដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗមិនគួរមានចំនួនលើសពី២០០ពាក្យឡើយ ហើយត្រូវដាក់បង្ហាញនៅលើផែនទាវីកបន្ថែម (មួយក្នុងម្នាក់/មួយគ្រួសារ) ដែលមាននិយាយអំពីរឿងរ៉ាវ និងរូបថតមួយសន្លឹករបស់ជនរងគ្រោះ។ អត្ថបទ

គួរសរសេរ និងផ្តល់ឱ្យជាខ្មែរអាត់សំឡេងជាភាសាខ្មែរ អង់គ្លេស និងបារាំង។ បូជនីយដ្ឋាននីមួយៗ គួរដាក់បញ្ចូលសេចក្តីសង្ខេបខ្លី និងលទ្ធផលនៃការជំនុំជម្រះលើកដំបូងនៅ អ.វ.ត.ក ដោយមិនឱ្យលើសពី៣០០ពាក្យ[54]។

៦៣. ដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើសុំឱ្យមានការប្រែក្លាយព្រៃស (មន្ទីរ ស-២៤) ទៅជាបូជនីយដ្ឋានដើម្បីចងចាំ, គោរពវិញ្ញាណក្ខន្ធជនរងគ្រោះ និងធ្វើបុណ្យតាមប្រពៃណីពុទ្ធសាសនា។ បន្ថែមពីលើនេះ ទីកន្លែងនេះគួរផ្តល់ព័ត៌មានអំពីប្រវត្តិសាស្ត្រ និងដើរតួនាទីមជ្ឈមណ្ឌលមួយសម្រាប់ការអប់រំទៅថ្ងៃអនាគត ដោយមានការពន្យល់ជាអចិន្ត្រៃយ៍អំពីមុខងារ និងតួនាទីរបស់ព្រៃស ដូចដែលបានបង្ហាញក្នុងសវនាការលើកដំបូងនៅ អ.វ.ត.ក និងយោងតាមលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រ។ ការពិតជាប្រវត្តិសាស្ត្រគួរត្រូវបានលាតត្រដាង ដូចជាតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទដែរ។ ការកសាងបូជនីយដ្ឋាននោះ គួរត្រូវបានសម្រេចតាមរយៈការប្រកួតប្រជែងផ្នែកស្ថាបត្យកម្មលក្ខណៈអន្តរជាតិ។ គួរមានចេតិយមួយដែលមានទំហំ២០ម៉ែត្រ គុណនឹង២០ និងកម្ពស់យ៉ាងហោចណាស់៣៥ម៉ែត្រ។ ផ្នែកខាងក្នុងគួរទុកឱ្យគេអាចមានលទ្ធភាពធ្វើបុណ្យតាមប្រពៃណីពុទ្ធសាសនា។ ដើមបណ្តឹងរដ្ឋប្បវេណីគួរសម្រេចថា តើសំណើណាមួយដែលពួកគាត់ពេញចិត្ត[55]។

៦៤. អ.ជ.ស.ដ ពុំពិចារណាទៅលើសំណើទាំងនេះឱ្យបានច្បាស់លាស់ឡើយ។ អ.ជ.ស.ដ បដិសេធ "សំណើសុំកសាងវត្ត និងបូជនីយដ្ឋានផ្សេងៗ" ដោយសំអាងថាខ្លួនគ្មានលទ្ធភាពបង្គាប់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឡើយដោយផ្អែកតាមសម្ភារៈដែលមាននៅចំពោះមុខខ្លួន ដោយហេតុថាសំណើនេះ "ខ្វះភាពជាក់លាក់គ្រប់គ្រាន់ពាក់ព័ន្ធនឹងចំនួនបូជនីយដ្ឋានពិតប្រាកដដែលស្នើសុំ និងប្រភេទ ទីតាំង ឬតម្លៃតាមការប៉ាន់ស្មាននៃបូជនីយដ្ឋានទាំងនោះ"[56]។

---

54 សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៥។

55 សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៦។

56 សាលក្រម, កថាខណ្ឌ៦៧២។

៦៥. ពិសេស អ.ជ.ស.ដ រិះគន់ថា "ពុំមានការផ្តល់ព័ត៌មានណាមួយឡើយ ឧទាហរណ៍ដូចជាព័ត៌មានពាក់ព័ន្ធនឹងអត្តសញ្ញាណនៃអ្នកកាន់កាប់ទីកន្លែងដែលបានស្នើសុំនោះ ថាតើពួកគាត់ឯកភាពនឹងការកសាងបូជនីយដ្ឋាននីមួយៗដែលបានស្នើឡើង ឬថាតើការអនុញ្ញាតពីផ្នែករដ្ឋបាលបន្ថែមដូចជាការអនុញ្ញាតឱ្យសាងសង់ នឹងចាំបាច់ដើម្បីផ្តល់ប្រសិទ្ធភាពដល់វិធានការនីមួយៗដែរឬទេ"[57]។

**មូលដ្ឋានទី ៥ នៃបណ្តឹងឧទ្ធរណ៍៖ ការបំពានវិធាន ២១ (១) (ក), ២១ (១) (គ) និងវិធាន ២៣**

៦៦. វិធាន ២១(១)(ក) និង ២១(១)(គ) ចែងថា ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពសិទ្ធិរបស់ជនរងគ្រោះ[58]។

៦៧. ប៉ុន្តែសំណើមានលក្ខណៈយ៉ាងពិស្តារ ហើយបានបញ្ជាក់យ៉ាងគ្រប់គ្រាន់អំពី ដោយសារសំណើនេះបញ្ជាក់ច្បាស់ពីចំនួន ប្រភេទ និងទីតាំងនៃបូជនីយដ្ឋាន។ លើសពីនេះទៅទៀត សំណើបានបញ្ជាក់យ៉ាងពិស្តារអំពីប្លង់រចនាបទនៃបូជនីយដ្ឋានទាំងនោះ។ វាជាផ្នែកមួយនៃសំណើ ដោយផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីនូវជម្រើសលើគម្រោងសំណើនានា ដែលនឹងត្រូវបង្ហាញជូនតាមរយៈការប្រកួតប្រជែងលើស្ថាបត្យកម្ម។

៦៨. នៅពេលស្នើសុំសេចក្តីពិស្តារជាងអ្វីដែលបានដាក់ជូន និងនៅពេលមិនពិនិត្យ ឬនៅពេលមើលរំលងសេចក្តីពិស្តារដែលមាននៅចំពោះមុខខ្លួន អង្គជំនុំជម្រះបានខកខានមិនបានគោរពតាមកាតព្វកិច្ចរបស់ខ្លួន ដែលត្រូវធានានូវការគោរពសិទ្ធិរបស់ជនរងគ្រោះ នៅក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធី ដូចបានចែងក្នុងវិធានផ្ទៃក្នុង ២១(១)(ក) និង (គ)។ សិទ្ធិទទួលបានសំណងក្លាយទៅជាគ្មានន័យ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ព័ត៌មានលម្អិតថែមទៀត។ អង្គជំនុំជម្រះសាលាដំបូង បានរៀបរាប់អំពីឧទាហរណ៍នៃកង្វះការឯកភាពពីកម្មសិទ្ធិករនៃទីតាំងទាំងនេះ និង/ឬ កង្វះលិខិតអនុញ្ញាតសាងសង់។ អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់ឱ្យបានច្បាស់ពីអ្វីដែលខ្លួនត្រូវការទេ ហើយលើសពីនេះទៅទៀត អង្គជំនុំ

---

[57] សាលក្រម កថាខណ្ឌ៦៧១។

[58] សូមមើល កថាខណ្ឌ៤៧ នៃបណ្តឹងសាទុក្ខនេះ។

ជម្រះសាលាដំបូងមិនបានជូនដំណឹងអំពីលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌ ដែលខ្លួនបានកំណត់ ដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីជាមុនឡើយ ថាតើត្រូវតែមានប្លង់ពីស្ថាបត្យករដាក់ភ្ជាប់ជាមួយសំណើដែរឬទេ? តើដើមបណ្តឹងរដ្ឋប្បវេណីចេញថ្លៃសោហ៊ុយលើការងារនេះតាមរបៀបណា? អង្គជំនុំជម្រះសាលាដំបូងបានបង្កើន និងពង្រីកបទដ្ឋានដែលមានលក្ខណៈសមរម្យរួចហើយ។ តាមពិត ការធ្វើបែបនេះនាំឱ្យភាគីមិនអាចធ្វើសំណើសុំសំណងបានឡើយ។ ការអនុវត្តបទដ្ឋានខ្ពស់ហួសហេតុ ដែលធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមិនអាចរកច្រកចេញបាន មានន័យថាអង្គជំនុំជម្រះសាលាដំបូងរារាំងសិទ្ធិទទួលបានសំណង ដោយបំពានទៅលើវិធាន ២១ នៃវិធានផ្ទៃក្នុង។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានជូនដំណឹងឱ្យជនរងគ្រោះបានដឹងជាមុន អំពីលក្ខណៈវិនិច្ឆ័យលើភាពអាចទទួលយកបាននៃសំណើសុំសំណង។

៦៩. ម្យ៉ាងវិញទៀត យើងមិនអាចរកឃើញមានមូលដ្ឋានផ្លូវច្បាប់ណាមួយនៅក្នុងវិធានផ្ទៃក្នុង កំណត់អំពីបទដ្ឋានខ្ពស់ ដែលអង្គជំនុំជម្រះសាលាដំបូងបានទាមទារនោះទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនមានបទប្បញ្ញត្តិចែងអំពីលក្ខខណ្ឌនៃការទាមទារសំណងរដ្ឋប្បវេណីឡើយ។

៧០. វិធាន ២៣(១)-(១៣) ចែងរៀបរាប់រាប់លម្អិតអំពីនីតិវិធីអនុវត្តចំពោះបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។ បទប្បញ្ញត្តិទាំងនេះបានកំណត់គ្រប់លក្ខខណ្ឌទាំងអស់ ដែលពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណី ដោយ *ក្នុងចំណោមលក្ខខណ្ឌទាំងនោះ* មានដូចជា លក្ខខណ្ឌចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬ ឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធី។

៧១. ប៉ុន្តែ យើងមិនឃើញមានលក្ខខណ្ឌដែលតម្រូវជាក់លាក់ពីដើមបណ្តឹងរដ្ឋប្បវេណី ដោយតម្រូវឱ្យមានការបញ្ជាក់ច្បាស់លាស់ នៅក្នុងសំណើទាមទារសំណងរបស់ខ្លួនឡើយ។ វិធាន ២៣(១)(ខ) ចែងអំពីគោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ដោយបញ្ជាក់ថា ជនរងគ្រោះ "ស្វែងរកសំណងផ្លូវចិត្ត និងសមូហភាព ដូចមានចែងនៅក្នុងវិធាននេះ"។ វិធាន ២៣(១១) ចែងថា អង្គជំនុំជម្រះអាចសម្រេចផ្តល់ឱ្យតែសំណងផ្លូវចិត្ត និងសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។

ហេតុដូច្នេះ យើងមិនអាចរកឃើញមានមូលដ្ឋានផ្លូវច្បាប់ណាមួយនៅក្នុងវិធានផ្ទៃក្នុង កំណត់អំពីបទដ្ឋានដ៏ខ្ពស់ហួសហេតុ ដែលអង្គជំនុំជម្រះទាមទារ ហើយដែលធ្វើឱ្យសំណើសុំសំណងទាំឡាយមិនអាចធ្វើទៅកើតនោះដែរ។

៧២. ទោះបីជាមានការទទួលស្គាល់ថា យន្តការនៅ អ.វ.ត.ក គឺកើតចេញពី "អ្នកដាក់ពាក្យបណ្តឹង"[59] ក៏ដោយ ក៏ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជាភាគីឯកជននោះ មិនអាចទទួលបន្ទុកតែឯងនៅក្នុងការប្រមូលព័ត៌មានលម្អិតបែបនេះ ដោយការចំណាយខ្លួនឯង ទាំងក្នុងការរៀបចំផែនការ និងការអនុវត្តយន្តការសំណង ដែលអាចនឹងទទួលបាននោះទេ។ អ.វ.ត.ក ហាក់ដូចជាមិនធ្វើការបែងចែករវាងបទដ្ឋានជាតិ ដែលអនុវត្តចំពោះការទាមទារសំណងជាថវិកាលើការខូចខាត និងបទដ្ឋានដែលអនុវត្តចំពោះការទាមទារសំណងរបស់ជនរងគ្រោះ ដែលគ្រាន់តែទាមទារនូវការបំពេញចិត្តតែប៉ុណ្ណោះ។ បទដ្ឋាននៃការបង្ហាញភស្តុតាង និងបទដ្ឋាននៃការបញ្ជាក់ឱ្យបានជាក់លាក់ចំពោះសំណើសុំសំណងទាមទារនូវការបំពេញចិត្ត គួរតែមានលក្ខណៈទាបជាងបទដ្ឋានលើការសុំសំណងជាថវិកា។ សំណងទាមទារការបំពេញចិត្តមានលក្ខណៈពិបាកសម្រាប់ភាគីទាមទារសំណងក្នុងការថ្លឹងថ្លែងជាងការទាមទារសំណងដទៃៗទៀត ប្រសិនបើភាគីទាមទារសំណងមិនមានជំនាញលើបញ្ហានេះ ឬមិនមានការជួយជ្រោមជ្រែងពីតុលាការ។ ជាពិសេស វាមានការពិបាកសម្រាប់ជនរងគ្រោះនៃការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស នៅក្នុងការបង្ហាញអំពីព្យសនកម្ម ដែលកើតមានចំពោះខ្លួន និងនៅក្នុងការបង្ហាញឱ្យបានជាក់លាក់នូវតម្លៃសំណងពិតប្រាកដ ប៉ុន្មានទសវត្សរ៍ក្រោយពេលដែលការរំលោភបំពានបានកើតឡើង។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានបង្ហាញយ៉ាងច្បាស់ថា បទដ្ឋាននៃការបង្ហាញភស្តុតាង ត្រូវតែបន្ថយនៅក្នុងករណីបែបនេះ ហើយ អ.វ.ត.ក គួរតែបង្កើតនូវវិធីសាស្ត្រជាក់ស្តែង ដែលអាចបត់បែន និងអនុវត្តទៅបាន ចំពោះសំណើសុំសំណង។

៧៣. ដូចបានបែងចែកយ៉ាងច្បាស់នៅក្នុងកថាខណ្ឌ ៣១ នៅពេលដែលវិធានផ្ទៃក្នុងមិនមានចែងលើបញ្ហាមួយនេះ ច្បាប់អន្តរជាតិគួរតែមានអានុភាពចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ សិទ្ធិ

---

[59] យោងខាងលើ កំណត់សម្គាល់លេខ១, កថាខណ្ឌ៦៥។

ទទួលបានសំណងដោយសមស្រប និងសមរម្យ គឺជាគោលការណ៍ច្បាប់អន្តរជាតិ[60] ដែលបានបង្កើតឡើង និងចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី[61] ហើយដែលមានចែងលម្អិតយ៉ាងលម្អិតនៅក្នុងគោលការណ៍មូលដ្ឋានរបស់ អ.ស.ប[62]។ ដោយសារ អ.វ.ត.ក ជាស្ថាប័នដែលបានបង្កើតឡើងដោយព្រះរាជាណាចក្រកម្ពុជា និងអង្គការសហប្រជាជាតិ អ.វ.ត.ក មានកាតព្វកិច្ចជួយសម្រួល និងជួយជ្រោមជ្រែងដល់ជនរងគ្រោះ[63] លើការទទួលបានសំណងឲ្យបានពេញលេញ[64] និងសមស្របបំផុតដែលខ្លួនអាចធ្វើទៅបាន ចំពោះព្យសនកម្ម ដែលបានកើតឡើងចំពោះជនរងគ្រោះ។ ដោយសារហេតុនេះ បទប្បញ្ញត្តិទាំងឡាយស្តីពីសំណង មិនត្រូវយកមកអនុវត្តដោយតឹងរ៉ឹងនោះទេ ប៉ុន្តែត្រូវយកមក

---

[60] *Permanent Court of International Justice, Factory at Chorzow (Claim for Indemnity) case, (រឿងក្តី Germany តទល់នឹង Poland), (អង្គសេចក្តី), PCIJ (ser. A) លេខ. 17, 1928, ទំព័រ. 29*, គោលការណ៍ និងបទដ្ឋានមូលដ្ឋានស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភធ្ងន់ធ្ងរលើច្បាស់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ, Res'n 2005/35 (ឯកសារ អ.ស.ប លេខ. E/CN.4/RES/2005/35 (2005)) និង GA Res'n 60/147 (ឯកសារ អ.ស.ប លេខ. A/RES/60/147 (2006))។

[61] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) (១៩៦៦) (មាត្រា. ២(៣), ៩(៥) និង ១៤(៦)) (សូមមើល គណៈកម្មកាសិទ្ធិមនុស្ស (HRC), យោបល់ទូទៅ (GC) លេខ. 31 [80] លក្ខណៈនៃកាតព្វកិច្ចទូទៅតាមផ្លូវច្បាប់លើរដ្ឋភាគីនៃកតិកាសញ្ញា 26/05/2004, (ឯកសារ អ.ស.ប លេខ CCPR/C/21/Rev.1/Add.13, ត្រង់កថាខណ្ឌ 15-17)។ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) (១៩៦៥) (មាត្រា៦)។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩) (មាត្រា៣៩)។ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្ម ឯទៀត ដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប (UNCAT) (១៩៨៤) (មាត្រា១៤) (សូមមើល គណៈកម្មការអង្គការសហប្រជាជាតិប្រឆាំងនឹងទារុណកម្ម (CAT), យោបល់ទូទៅលេខ 2, *Implementation of Article 2 by States Parties*, (ឯកសារ អ.ស.ប លេខ CAT/C/GC/2/CRP. 1/Rev.4 (2007).) ត្រង់កថាខណ្ឌ 15)។ និងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (១៩៩៨) (មាត្រា៧៥)។

[62] គោលការណ៍មូលដ្ឋានរបស់ អ.ស.ប, យោងខាងលើ កំណត់សម្គាល់លេខ ២៩។

[63] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ១២(គ) និង១៣។

[64] *Permanent Court of International Justice, Factory at Chorzow (Claim for Indemnity) case, (រឿងក្តី Germany តទល់នឹង Poland), (អង្គសេចក្តី), PCIJ (ser. A) លេខ. 17, 1928, ទំព័រ 29* ។

អនុវត្តក្នុងលក្ខណៈមួយ ដែលមានប្រសិទ្ធភាពនៅក្នុងការអនុវត្ត[65]។ ការដាក់បន្ទុកមួយខ្ពស់ និងមិនសមហេតុផលលើដើមបណ្តឹងរដ្ឋប្បវេណី ដោយតម្រូវឱ្យបញ្ជាក់លើតម្លៃសំណង និង ព័ត៌មានលម្អិតនៃសំណើទាមទារសំណង មិនមែនជាការបំពេញលក្ខខណ្ឌនេះឡើយ ហើយវាបែរ ជាផ្ទុយនឹងផលប្រយោជន៍នៃយុត្តិធម៌ទៅវិញ។ ទោះបីជាមានការជួយជ្រោមជ្រែងពីភាគីនានា ក៏ដោយ ការងារចុងក្រោយលើការកំណត់លើការទាមទារសំណងដែលមានលក្ខណៈសមស្រប និងសមភាព សម្រាប់ភាគីដែលទទួលរងនូវព្យសនកម្ម គឺស្ថិតនៅលើអ្នកធ្វើសេចក្តីសម្រេច។ ចំណុចនេះបានបង្កើតឡើងយ៉ាងច្បាស់ តាមរយៈការអនុវត្តក្នុងក្របខណ្ឌអន្តរជាតិ ដែលនឹងលើក ឡើងនៅក្នុងកថាខណ្ឌខាងក្រោមនេះ។

៧៤. តុលាការអន្តរទ្វីបអាមេរិកផ្នែកសិទ្ធិមនុស្ស ("តុលាការអន្តរទ្វីបអាមេរិក") គឺជាស្ថាប័នតុលាការ មួយ ដែលដោះស្រាយលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការ នេះកាលពីជាងម្ភៃឆ្នាំមុន តុលាការនេះបានបង្កើតគំរូថ្មីមួយចំពោះសំណង ហើយតុលាការនេះនៅ តែដើរតួនាំមុខគេនៅក្នុងការបង្គាប់ និងអនុវត្តសំណងជាសមូហភាព និងសំណងផ្លូវចិត្តចំពោះ ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ[66]។ ហេតុដូច្នេះ តុលាការអន្តរទ្វីបអាមេរិកនេះ បានកំណត់សំណង ដែលសមស្រប ហើយមិនចងកាតព្វកិច្ចខ្លួនឯងទៅតាមសំណើសុំរបស់ជនរងគ្រោះឡើយ។

៧៥. តុលាការអន្តរទ្វីបអាមេរិក មិនបានបង្កើតលក្ខខណ្ឌឱ្យជនរងគ្រោះបញ្ជាក់ឱ្យបានជាក់លាក់នៅក្នុង បណ្តឹងទាមទារសំណងរបស់ខ្លួនឡើយ។ ប៉ុន្តែ តុលាការនេះខ្លួនឯង "បានរកឃើញនូវវិធីសាស្ត្រច្នៃ ប្រឌិត នៅក្នុងការដោះស្រាយលើតម្រូវការជាក់លាក់ និងសំណងរបស់ជនរងគ្រោះ ដែលចូលខ្លួន នៅចំពោះមុខតុលាការ"[67]។ តុលាការនេះបានបង្គាប់ឱ្យមានសំណងមួយចំនួន ដែលមានលក្ខណៈ

---

[65] យោបល់ទូទៅលេខ 31, កថាខណ្ឌ20, យោងខាងលើ កំណត់សម្គាល់លេខ 27។ គោលការមូលដ្ឋានរបស់ អ.ស.ប មាត្រា១១(ខ), យោងខាងលើ កំណត់សម្គាល់លេខ 29។

[66] អត្ថបទរបស់ Bridget Mayeux/Justin Mirabal, មានចំណងជើងថា "Collective and Moral Reparations in the Inter-American Court of Human Rights," Human Rights Clinic, បោះពុម្ពដោយ The University of Texas School of Law, ឆ្នាំ2009, ទំព័រ. 1។

[67] យោងខាងលើ ទំព័រ8។

ស្រដៀងនឹងសំណាងទាំងឡាយ ដែលបានស្នើសុំនៅចំពោះមុខ អ.វ.ត.ក ឧទាហរណ៍ ដូចជា ការកសាងបូជនីយដ្ឋាន ការយកឈ្មោះជនរងគ្រោះដាក់ជាឈ្មោះផ្លូវ[68] ការផ្តល់លទ្ធភាពលើការទទួលការថែទាំផ្នែកវេជ្ជសាស្ត្រ និងចិត្តសាស្ត្រ[69] លទ្ធកម្មលើផែនការអភិវឌ្ឍន៍[70] និងការសុំខមាលទោសជាសាធារណៈ[71]។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ បទដ្ឋានដែលតម្រូវឲ្យជនរងគ្រោះ ឬអ្នកតំណាងរបស់ពួកគេ បញ្ជាក់លើការទាមទារសំណងឲ្យបានជាក់លាក់នៅក្នុងករណីទាំងនេះ គឺមានលក្ខណៈទាបជាងបទដ្ឋាន ដែលអនុវត្តដោយ អ.វ.ត.ក ជាពិសេសចំពោះករណីទាំងឡាយ ដែលមានជនរងគ្រោះច្រើន និងចំពោះករណី ដែលការរំលោភបំពានទាំងឡាយបានកើតឡើងជាច្រើនឆ្នាំមកហើយ ដោយតុលាការបានដាក់បន្ទុកមួយចំនួនដល់រដ្ឋនៅក្នុងការអនុវត្តការបង្គាប់លើសំណងវិញ។ ហើយតុលាការអន្តរទ្វីបអាមេរិក បានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងការបញ្ជាក់បណ្តឹងទាមទារសំណងវិញ។

៧៦. ឧទាហរណ៍ ចំពោះការកសាងបូជនីយដ្ឋាននៅក្នុងករណី *Myrna Mack Chang* ជនរងគ្រោះទាំងឡាយគ្រាន់តែបានលើកឡើងថា ខ្លួនមានបំណងចង់ឲ្យកសាង "បូជនីយដ្ឋានមួយសម្រាប់ Myrna Mack Chang ដាក់នៅតំបន់ Guatemala ដែលស្ត្រីរងគ្រោះរូបនេះធ្លាប់បម្រើការងារនៅទីនោះ"[72]។ តុលាការអន្តរទ្វីបអាមេរិក ក៏បានស្នើសុំឲ្យរដ្ឋដាក់ឈ្មោះ "ផ្លូវ ឬទីតាំងល្បីមួយ" ដើម្បីគោរពដល់ជនរងគ្រោះនោះ[73]។ តាមរយៈករណីនេះ យើងអាចមើលឃើញថា

---

[68] *រឿងក្តី Myrna Mack-Chang តទល់នឹង Guatemala*, IACtHR, ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០០៣, កថាខណ្ឌ 286, Series C No. 101។

[69] សូមមើល ឧទាហរណ៍, *រឿងក្តី Children's Rehabilitation តទល់នឹង Paraguay*, IACtHR, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៤, កថាខណ្ឌ 318-320, Series C No.112។ *រឿងក្តី Plan de Sánchez Massacre តទល់នឹង Guatemala*, IACtHR, ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៤, កថាខណ្ឌ107-108, Series C No.105។

[70] *រឿងក្តី Children's Rehabilitation* តទល់នឹង *Paraguay*, IACtHR, ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៤, កថាខណ្ឌ 316-317, Series C No.112។

[71] *រឿងក្តី Plan de Sánchez Massacre តទល់នឹង Guatemala, យោងខាងលើ លេខ.23*, កថាខណ្ឌ100-101។

[72] *រឿងក្តី Myrna Mack-Chang តទល់នឹង Guatemala*, កថាខណ្ឌ 270(ឃ)(iii)។

[73] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ 286។

សំណងដែលបានស្នើសុំដោយជនរងគ្រោះ មានលក្ខណៈទូទៅជាងសំណង ដែលបានស្នើសុំនៅចំពោះមុខ អ.វ.ត.ក ហើយដីកាបង្គាប់របស់តុលាការអន្តរទ្វីបអាមេរិកបានផ្ដល់ជម្រើសដល់រដ្ឋនូវវិធីសាស្ត្រនៅក្នុងអនុវត្តដីកាបង្គាប់។ នៅក្នុងករណី *Plan de Sáchez* តុលាការបានបង្គាប់ឱ្យបង្កើតនូវកម្មវិធីអភិវឌ្ឍន៍មួយ ហើយគ្រាន់តែតម្រូវឱ្យបញ្ជាក់ថាវានឹងផ្ដល់ផលប្រយោជន៍ដល់សហគមន៍ណាខ្លះ និងសង្ខេបនូវវិធានការទូទៅនេះតែប៉ុណ្ណោះ ឧទាហរណ៍ ដូចជា ការកសាងផ្លូវ[74]។ នៅពេលធ្វើសំណើទាមទារសំណង ជនរងគ្រោះបានបញ្ជាក់នូវលក្ខខណ្ឌអប្បបរមានៃវិជ្ជាជីវៈពេទ្យចាំបាច់តែប៉ុណ្ណោះ ដែលជាលក្ខខណ្ឌទាមទារនៅក្នុងផ្នែកមួយនៃកម្មវិធីនេះ ដោយទុកលក្ខខណ្ឌដែលនៅសល់ឱ្យរដ្ឋជាអ្នកធ្វើឡើង[75]។ នៅក្នុងចំណុចចុងក្រោយ នៅពេលទាមទារឱ្យមានការសាងសង់បូជនីយដ្ឋានមួយ ជនរងគ្រោះទាំងឡាយ បានស្នើសុំឱ្យរដ្ឋ ដោយធ្វើការសម្របសម្រួលជាមួយនឹងសង្គមស៊ីវិលនៅក្នុងមូលដ្ឋាន ជាអ្នករៀបចំលក្ខណៈ និងផលប្រយោជន៍សំខាន់នៃបូជនីយដ្ឋាននោះ[76]។

៧៧. តុលាការអន្តរទ្វីបអាមេរិកត្រូវបានគេគោរព ដោយសារតែឯកត្តកម្មលើការបង្គាប់សំណងរបស់ខ្លួន ដូច្នេះ អ.វ.ត.ក គួរតែពិនិត្យមើលបទពិសោធន៍របស់តុលាការនេះ នៅពេលកំណត់គោលនយោបាយលើសំណងរបស់ខ្លួន។ តុលាការអន្តរទ្វីបអាមេរិក បានកែសម្រួលបទដ្ឋាននៃការបង្ហាញភស្តុតាង និងបទដ្ឋាននៃការបញ្ជាក់មូលដ្ឋានចំពោះបណ្ដឹងទាមទារសំណង ដែលតម្រូវចំពោះជនរងគ្រោះឱ្យស្របតាមភាពចាំបាច់ និងកាលៈទេសៈនានានៃរឿងក្ដីនីមួយៗ។ តុលាការក៏ផ្ដល់ការជួយជ្រោមជ្រែងសំខាន់ៗដល់ជនរងគ្រោះ នៅក្នុងការបង្កើតបណ្ដឹងទាមទារសំណង ជាពិសេសចំពោះសំណងនិមិត្តរូប។ ការជួយជ្រោមជ្រែងជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងជាលក្ខណៈប្រព័ន្ធ នៅក្នុងពេលសវនាការ គឺមានសារៈសំខាន់យ៉ាងច្បាស់ ដើម្បីឱ្យជនរងគ្រោះអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងការទទួលបានសំណងសមស្រប និងសមរម្យ។

---

74 *រឿងក្ដី Plan de Sánchez Massacre តទល់នឹង Guatemala*, កថាខណ្ឌ 109-110។

75 *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៩១(ឃ)។

76 *រឿងក្ដី Plan de Sánchez Massacre តទល់នឹង Guatemala*,កថាខណ្ឌ91(គ)។

៧៨. នាពេលបច្ចុប្បន្ន បទដ្ឋានដែលតម្រូវឱ្យមានការបញ្ជាក់ឱ្យបានជាក់លាក់លើការទាមទារសំណង ដែលអង្គជំនុំជម្រះអនុវត្ត គឺមានលក្ខណៈស្រពិចស្រពិល ដោយសារមូលដ្ឋាននៃអង្គច្បាប់ ពោលគឺ វិធានផ្ទៃក្នុងមិនមានចែង ហើយច្បាប់ជាតិកម្ពុជាចំពោះឧបាស្រ័យលើការទាមទារសំណងនោះក៏ មិនបានបញ្ជាក់ផងដែរ។ ដូច្នេះ អ.វ.ត.ក គួរពិនិត្យមើលបទដ្ឋានណែនាំរបស់តុលាការព្រហ្មទណ្ឌ អន្តរជាតិ ដែលមានប្រព័ន្ធស្រដៀងគ្នាលើការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ច ដំណើរការនីតិវិធីព្រហ្មទណ្ឌ អនុលោមតាមច្បាប់អន្តរជាតិ។ បន្ថែមពីនេះ អ.វ.ត.ក គួរយក បទពិសោធន៍ពីតុលាការនៅក្នុងតំបន់នានា ដូចជា តុលាការអន្តរទ្វីបអាមេរិកនេះជាដើម។ លក្ខន្តិកៈទីក្រុងរ៉ូម ក៏ជាប្រភពមួយសំខាន់ខ្លាំងណាស់ដែរ សម្រាប់ អ.វ.ត.ក ដោយសារប្រទេស កម្ពុជាគឺជាភាគីហត្ថលេខីលើលក្ខន្តិកៈនេះ ហើយត្រូវគោរពតាមបទប្បញ្ញត្តិស្តីពី "ការបំពេញបន្ថែម" ផងដែរ[77]។

៧៩. តុលាការព្រហ្មទណ្ឌអន្តរជាតិ កំណត់ទម្រង់ដ៏សមស្របលើសំណង ដែលត្រូវសម្រេចជំនួសឱ្យ ជនរងគ្រោះ ដោយត្រូវផ្អែកលើមូលដ្ឋានសមធម៌។ ហេតុដូច្នេះ អនុលោមតាមមាត្រា ៧៥(១) នៃ លក្ខន្តិកៈទីក្រុងរ៉ូម "តុលាការត្រូវបង្កើតជាគោលការណ៍ ដែលទាក់ទងដល់ការជួសជុល... ដោយឈរលើមូលដ្ឋាននេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការអាចកំណត់តាមសំណើរ ឬ តាមការស្នើរបស់ខ្លួននៅក្នុងកាលៈទេសៈពិសេសៗ" នូវកម្រិតវិសាលភាព និងទំហំនៃព្យសនកម្ម។ វិធាន ៩៤ ចែងថា ក្នុងករណីជនរងគ្រោះដាក់សំណើសុំសំណង អនុលោមតាមមាត្រា ៧៥ ជនរងគ្រោះនោះត្រូវផ្តល់ព័ត៌មានលម្អិតនៃព្យសនកម្មដែលទទួលរង ការរៀបរាប់អំពីទ្រព្យសកម្ម ទ្រព្យសម្បត្តិ ឬវត្ថុដទៃៗទៀត ដែលបានទាមទារឱ្យធ្វើបដិទាន និងការទាមទារជាក់លាក់ ជាសំណងថវិកា ការស្តារនីតិសម្បទា ឬ ទម្រង់នៃឧបាស្រ័យដទៃៗទៀត។ ចំនុចចុងក្រោយ វិធានចែងថា ជនរងគ្រោះគួរផ្តល់ "ឯកសារគាំទ្រដែលពាក់ព័ន្ធ *ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន*" (គូសបញ្ជាក់បន្ថែម)។ ហេតុដូច្នេះ វិធានទាំងនេះ មិនបានកំណត់ បទដ្ឋាននៃការបញ្ជាក់ឱ្យបានជាក់លាក់ ឱ្យមានលក្ខណៈខ្ពស់ហួសហេតុចំពោះបណ្តឹងទាមទារ

---

77 មាត្រា១៧(១)(១) លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។

សំណាងរបស់ជនរងគ្រោះនោះទេ ប៉ុន្តែបានអនុញ្ញាតឱ្យមានបទដ្ឋានក្នុងលក្ខណៈបត់បែន ហើយ ផ្តល់ឲ្យតុលាការជាអ្នកកំណត់វិសាលភាព និងទម្រង់នៃសំណង ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនវិញ។ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺ ក្នុងករណីមានភាពមិនច្បាស់លាស់ តុលាការអាច ពិចារណាលើការរៀបរាប់ពីអ្នកតំណាងរបស់ជនរងគ្រោះ និងភាគីដែលពាក់ព័ន្ធដទៃៗទៀត (មាត្រា ៧៥(៣) នៃលក្ខន្តិកៈទីក្រុងរ៉ូម) ហើយអាចតែងតាំងអ្នកជំនាញដែលពាក់ព័ន្ធបាន (វិធាន ៩៧(២) នៃវិធានផ្ទៃក្នុង ដើម្បីជួយជ្រោមជ្រែងនៅក្នុងការកំនត់ប្រភេទ និងគំរូនៃសំណង ឱ្យបានសមស្រប។

៨០. បន្ថែមពីនេះ នៅក្នុងឯកសារអន្តរជាតិដទៃៗទៀត ដូចជា គោលការណ៍មូលដ្ឋានរបស់ អ.ស.ប ឬ លិខិតុបករណ៍ដែលពាក់ព័ន្ធដទៃៗទៀត ដែលធានាឱ្យមានសំណងសមរម្យសម្រាប់ជនរងគ្រោះ នៃការរំលោភសិទ្ធិមនុស្ស[78] មិនទាមទារឱ្យធ្វើសំណើលម្អិតបំផុតចំពោះសំណងនោះទេ។

៨១. ដោយសារហេតុនេះ នៅពេលទាមទារឱ្យធ្វើសំណើមួយដោយត្រូវបញ្ជាក់ឱ្យបានជាក់លាក់ ដោយ គ្មានមូលដ្ឋានច្បាប់ចែងនោះ អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមនីតិវិធី មិនគោរពតាម គោលការណ៍យុត្តិធម៌ និងសិទ្ធិរបស់ជនរងគ្រោះ ដែលជាហេតុរំលោភលើវិធាន ២១(១)(ក) និង(គ) និងវិធាន ២៣ នៃវិធានផ្ទៃក្នុង។

៨២. ចំណុចចុងក្រោយ ការទាមទាររបស់អង្គជំនុំជម្រះឱ្យផ្តល់ព័ត៌មានអំពីអត្តសញ្ញាណរបស់កម្មសិទ្ធិ ករនៃទីកន្លែង ការឯកភាពពីកម្មសិទ្ធិករទាំងនេះចំពោះការសាងសង់បូជនីយដ្ឋាននីមួយៗដែលបាន ស្នើសុំ និងតម្រូវការសុំការអនុញ្ញាតពីអាជ្ញាធររដ្ឋបាល ដូចជា លិខិតអនុញ្ញាតលើការសាងសង់ គឺជាការទាមទារហួសពីលក្ខខណ្ឌ ដែលតម្រូវឱ្យធ្វើសំណើមួយដែលត្រូវបញ្ជាក់ឱ្យបានគ្រប់គ្រាន់ និងដែលអាចធ្វើទៅបានតែប៉ុណ្ណោះ។

៨៣. បន្ថែមពីនេះ ការផ្តល់ព័ត៌មានលម្អិតដូចជា ការអនុញ្ញាតពីអាជ្ញាធររដ្ឋបាល ឬ ការពន្យល់លើផែនការ

---

[78] ឧទាហរណ៍, កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ, ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, 999 U.N.T.S. 171, មាត្រា២ (៣), និង អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍, ១៩៦៥, 660 U.N.T.S. 195, 199, មាត្រា៦, អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ, ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩, 1577 U.N.T.S. 3, 56, មាត្រា 39។

គឺជាការដាក់បន្ទុកធំធេងដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ ពោល នេះគឺបានន័យថាជាការចំណាយធនធានបន្ថែមហួសហេតុ ដូចជា ការចំណាយថវិកា ដែលជនរងគ្រោះគ្មាន។ ប្រភេទនៃលក្ខខណ្ឌបែបនេះ គឺជាការរាំងមិនឱ្យធ្វើសំណើសុំសំណង ហើយបង្កើតជាការរំលោភគោលការណ៍យុត្តិធម៌ និងកាតព្វកិច្ចក្នុងការការពារផលប្រយោជន៍របស់ជនរងគ្រោះ អនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង។

## មូលដ្ឋានទី៦ នៃបណ្ដឹងឧទ្ធរណ៍៖ ការភ័ន្តច្រឡំលើអង្គហេតុ

៨៤. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ នៅពេលខ្លួនបដិសេធសំណើ ដោយឈរលើមូលដ្ឋានថា មិនមានការបញ្ជាក់ឱ្យបានជាក់លាក់។ អង្គជំនុំជម្រះសាលាដំបូងបានមើលរំលង និងមិនបានពិចារណាលើព័ត៌មានលម្អិត ដែលបានដាក់ជូននៅក្នុងសំណើ។

៨៥. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមសន្និដ្ឋានថា ដីកាសម្រេចបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំលើអង្គហេតុ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើព័ត៌មានលម្អិតដែលបានដាក់ជូននោះ អង្គជំនុំជម្រះសាលាដំបូងប្រាកដជាទទួលស្គាល់ថា សំណើនេះបានបញ្ចូលព័ត៌មានលម្អិតគ្រប់គ្រាន់។ ដូច្នេះ ការភ័ន្តច្រឡំលើអង្គហេតុនេះនាំឱ្យមានកំហុសធ្ងន់ធ្ងរនៃយុត្តិធម៌ ដោយសារវាបានធ្វើឱ្យដើមបណ្ដឹងរដ្ឋប្បវេណីមិនទទួលបានសំណង។

## ខ. សំណើទី ៥៖ ការផ្ដល់សោហ៊ុយដល់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ការធ្វើទស្សនកិច្ចនៅបូជនីយដ្ឋាននានា

៨៦. ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំថា ខ្លួនគួរតែទទួលបានសោហ៊ុយសម្រាប់ការធ្វើទស្សនកិច្ចនៅបូជនីយដ្ឋាននានា ដូចជា នៅទួលស្លែង ជើងឯក និងព្រៃស ចំនួន ៣ ដង ក្នុងមួយឆ្នាំ ដោយការធ្វើទស្សនកិច្ចម្ដងៗមានរយៈពេល ៤ ថ្ងៃ។ ក្នុងនោះគួររួមបញ្ចូលទាំងសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ដោយអាចឱ្យមនុស្សទទួលបានការអនុញ្ញាតពីខ្លួន ទៅធ្វើទស្សនកិច្ចជំនួសខ្លួន

បាន ឬ/និងមានមនុស្សម្នាក់ទៀតអមដំណើរទៅជាមួយផងដែរ នៅក្នុងករណីចាំបាច់[79]។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចលើសំណើនេះទេ។

**មូលដ្ឋានទី៧ នៃបណ្តឹងឧទ្ធរណ៍៖ ការរំលោភបំពានលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង**

៨៧. វិធាន ១០០(១) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង នៅពេលខ្លួនមិនបានសម្រេចលើសំណើនេះ។

**មូលដ្ឋានទី៨ នៃបណ្តឹងឧទ្ធរណ៍៖ ការភ័ន្តច្រឡំលើអង្គច្បាប់**

៨៨. ដីកាសម្រេចបដិសេធ គឺបានផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំអង្គហេតុ នៅពេលមិនធ្វើការសម្រេចលើសំណើនេះទាល់តែសោះនោះ។ ការភ័ន្តច្រឡំលើអង្គហេតុនេះនាំឱ្យមានកំហុសឆ្គងនៃយុត្តិធម៌ ដោយសារវាបានធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានសំណង ហើយវាបានធ្វើឱ្យសាលក្រមមោឃៈ។

## ឈ. សំណើទី ៦÷ ការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងសេវាចិត្តសាស្ត្រសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី

៨៩. ភាគីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំសិទ្ធិទូទៅ ក្នុងការទទួលបានការព្យាបាលវេជ្ជសាស្ត្រគ្រប់ប្រភេទ ដែលរួមបញ្ចូលទាំងការគាំទ្រខាងចិត្តសាស្ត្រ យ៉ាងហោចណាស់សម្រាប់អ្នករស់រានមានជីវិតផ្ទាល់ពី ស-២១ និងសម្រាប់អ្នករងគ្រោះដោយប្រយោល ប្រសិនបើពួកគេអាចបង្ហាញភស្តុតាងបឋមថា ការឈឺចាប់របស់គេត្រូវបានបង្កឡើង ឬអាចបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ។ កាំង ហ្កេកអ៊ាវ ត្រូវទទួលបន្ទុកក្នុងការចេញចំណាយសម្រាប់ការព្យាបាល ថ្លៃថ្នាំពេទ្យ និងក្នុងករណីចាំបាច់ ត្រូវចេញថ្លៃធ្វើដំណើរ[80]។ សំណើសុំមានភាពច្បាស់លាស់ និងមានន័យជាក់លាក់ថា ជនជាប់ចោទត្រូវទទួលបន្ទុកក្នុងថ្លៃចំណាយសម្រាប់សំណងនេះ ហើយ

---

[79] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៧។

[80] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៨។

សំណាងស្ថិតក្នុងវិសាលភាពដែលអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចបាន។

៩០. ទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះដោយផ្អែកលើមូលដ្ឋានបី៖ (១) សំណើប្រភេទនេះមិនមានលក្ខណៈជាសំណងនិមិត្តរូបទេ (២) ប៉ុន្តែបម្រើផលប្រយោជន៍ជនរងគ្រោះច្រើននាក់ និង (៣) ស្ថិតនៅក្រៅវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេចបាន ដោយសារតុលាការមិនអាចដាក់កាតព្វកិច្ចដល់អាជ្ញាធរសុខាភិបាលជាតិបានឡើយ[81]។

៩១. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានយល់ខុសលើអត្ថន័យនៃសំណើ ដោយសារសំណើនេះមិនបានសុំឱ្យផ្តល់ការព្យាបាលវេជ្ជសាស្ត្រ និងសេវាកម្មចិត្តសាស្ត្រ ដើម្បីបម្រើផលប្រយោជន៍ជនរងគ្រោះច្រើននាក់ទេ។ ផលប្រយោជន៍ទាំងនេះគួរផ្តល់តែអ្នករស់រានមានជីវិតផ្ទាល់ពី ស-២១ និង ស-២៤ និងអ្នករងគ្រោះដោយប្រយោល។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំមានចំនួនសរុបតែ ១៧នាក់ ដោយរួមទាំងអ្នកដាក់ពាក្យសុំ ៥រូប ដែលត្រូវបានបដិសេធផងដែរ។

៩២. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានយល់ខុសលើសំណើដែលមានអត្ថន័យច្បាស់ និងជាក់លាក់ ដែលមិនបានសំដៅឱ្យរាជរដ្ឋាភិបាលកម្ពុជាដំណើរការ ឬបង្កើតមជ្ឈមណ្ឌលសុខភាពនោះទេ ប៉ុន្តែបានស្នើសុំឱ្យតុលាការបង្គាប់ឱ្យជនជាប់ចោទ ទទួលបន្ទុកលើការចំណាយលើការព្យាបាល ថ្លៃថ្នាំពេទ្យ និងក្នុងករណីចាំបាច់ ត្រូវចេញថ្លៃធ្វើដំណើរ ដោយមិនគិតពីបុគ្គល/ស្ថាប័នដែលផ្តល់សេវាកម្មឡើយ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការភ្ញាក់ផ្អើល ដោយសារគ្រាន់តែសំណើច្បាស់និងជាក់លាក់បែបនេះ ក៏អាចធ្វើឱ្យអង្គជំនុំជម្រះយល់ខុសបានដែរ។

## មូលដ្ឋានទី ៩៖ ការបំពានវិធាន ២៣ (១)(ខ)

៩៣. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្អែកលើការយល់ខុសអំពីពាក្យ "សំណងសមូហភាព និងសំណងផ្លូវចិត្ត" ដែលបានចែងក្នុងវិធាន ២៣(១)(៣) នៃវិធានផ្ទៃក្នុង។

---

[81] សាលក្រម, កថាខណ្ឌ ៦៧៤។

៩៤. ជាបឋម សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា សំណងសមូហភាព និងសំណងផ្លូវចិត្ត មានចេតនាស្តារសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ និងទប់ស្កាត់ការបំពានសិទ្ធិមនុស្សក្នុងពេលអនាគត។ រាល់វត្ថុ ឬវិធានការនៃសំណងមានអត្ថន័យជាសំណងនិមិត្តរូបចំពោះបុគ្គលទាំងឡាយ[82]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបដិសេធសំណើសុំដោយសារសេវាកម្មសុខាភិបាល "មិនមែនលក្ខណៈជាសំណងនិមិត្តរូបទេ"។ ដូច្នេះ វានៅតែមានន័យមិនច្បាស់ដដែល ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអះអាងថា "ខ្លួនមិនអាចសម្រេចលើសំណើសុំសេវាសុខាភិបាលបាន ដោយសារវាមិនស្ថិតក្នុងប្រភេទនៃ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត"។

៩៥. អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានកំណត់និយមន័យនៃពាក្យ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត"។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចត្រឹមតែសន្និដ្ឋានចេញពីសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងថា "សំណើនេះមិនមានលក្ខណៈជាសំណើនិមិត្តរូបទេ" ដែលឃ្លានេះមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានទស្សនៈស្រពិចស្រពិលលើអត្ថន័យនៃសំណងរដ្ឋប្បវេណីក្នុងវិធាន ២៣ ថាកម្រិតត្រឹមតែសំណងនិមិត្តរូប។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងយល់ខុស និងមានកំហុសក្នុងការគិតដូច្នេះ ដោយហេតុថាជាគោលការណ៍ រាល់វិធានការឬវត្ថុនៃសំណង មានលក្ខណៈជាសំណងនិមិត្តរូប។

៩៦. ច្បាប់បានកំណត់ចំណាត់ថ្នាក់នៃទម្រង់សំណងតែប្រាំ ដែលរួមមាន៖ បដិទាន សំណងជំងឺផ្លូវចិត្ត ការស្តារនីតិសម្បទា ការជំរះកាតព្វកិច្ច ឬការធានាកុំឱ្យកើតជាថ្មី[83]។ សំណងសមូហភាព និងសំណងផ្លូវចិត្ត មិនត្រូវបានរាប់បញ្ចូលក្នុងចំណាត់ថ្នាក់នៃសំណងនេះឡើយ។

៩៧. ដូច្នេះ ក្នុងករណីដែលគ្មានការណែនាំច្បាស់លាស់ អង្គជំនុំជម្រះត្រូវបកស្រាយចំណុចប្រសព្វគ្នា

---

[82] អត្ថបទរបស់ Brandon Hamber, មានចំណងជើងថា "ការបំពេញគោលការណ៍មីក្រូនិងម៉ាក្រូ៖ ទស្សនវិស័យចិត្តសាស្ត្រស្តីពីសំណងរដ្ឋប្បវេណីក្នុងសង្គមដែលស្ថិតក្នុងអន្តរកាល" នៅក្នុង៖ សៀវភៅណែនាំស្តីពីសំណងរដ្ឋប្បវេណី មជ្ឈមណ្ឌលយុត្តិធម៌អន្តរកាល (ប្រែសម្រួល), បោះពុម្ពដោយ Oxford University Press, (ឆ្នាំ 2006), ទំព័រ 560-588 (565)។

[83] សូមមើល គោលការណ៍មូលដ្ឋាន យោងខាងលើ កំណត់សម្គាល់លេខ 29, កថាខណ្ឌ18-23។

00623077



រវាងសំណងសមូហភាព និងសំណងផ្លូវចិត្ត ឲ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ដើម្បីគ្របដណ្តប់ដល់វិសាលភាពនៃការអនុវត្តឲ្យបានធំធេងតាមដែលអាចធ្វើទៅបាន ដើម្បីខិតទៅរកបទដ្ឋានអន្តរជាតិឲ្យបានជិតបំផុត តាមដែលអាចធ្វើទៅបាន។

៩៨. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចសន្និដ្ឋានថែមទៀតថាការយល់ស្រពិចស្រពិល និងមិនជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូងអំពី "សំណងសមូហភាព និងសំណងផ្លូវចិត្ត" ថាជាផលប្រយោជន៍បុគ្គលក្នុងការទទួលបានសេវាកម្មសុខភាពផ្លូវចិត្ត ហើយមិនត្រូវបានទុកជាសំណងនិមិត្តរូបទេ ដោយសារតែបុគ្គលទទួលបានការថែទាំសុខភាព ហេតុដូច្នេះសំណងប្រភេទនេះមិនមែនជាសំណងសមូហភាព និងសំណងផ្លូវចិត្តឡើយ។

៩៩. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការចាត់ទុកថាសេវាថែទាំសុខភាពគឺ "មិនមានលក្ខណៈជាសំណងនិមិត្តរូប" ដូច្នេះហើយមិនអាចស្ថិតនៅក្នុងប្រភេទ "សំណងសមូហភាព និងសំណងផ្លូវចិត្ត" ឡើយ។

១០០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សង្កេតឃើញថា វិធានផ្ទៃក្នុងមិនបានកំណត់និយមន័យនៃពាក្យថា "សំណងសមូហភាព និងសំណងផ្លូវចិត្ត" ឯកសារនៃដំណើរការរៀបចំសេចក្តីព្រាងវិធានផ្ទៃក្នុង មិនអាចរកបានទេ ដោយសារកិច្ចប្រជុំពេញអង្គជាកិច្ចប្រជុំសម្ងាត់ ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់ពួកគេមិនអាចរកឯកសារនេះបានឡើយ[84]។

---

[84] វិធាន ១៨(១០) នៃវិធានផ្ទៃក្នុងចែងថា លើកលែងតែកិច្ចប្រជុំពេញអង្គសម្រេចផ្សេងពីនេះ ឯកសារកិច្ចប្រជុំពេញអង្គគឺជាឯកសារសម្ងាត់។ តាមដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដឹង គ្មានការបោះពុម្ពផ្សាយនូវកំណត់ពន្យល់ដែលរៀបរាប់ថា "សំណងផ្លូវចិត្តនិងសំណងសមូហភាព" មានលក្ខណៈបែបណាឡើយ។ មានតែសេចក្តីប្រកាសព័ត៌មានស្តីពីការអនុម័តវិធានផ្ទៃក្នុង ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៧, ដែលការចង្អុលបង្ហាញថាសំណងសមូហភាព គឺជាសំណងមិនមែនហិរញ្ញវត្ថុ។ "ប៉ុន្តែ ដោយសារលក្ខណៈពិសេសរបស់ អ.វ.ត.ក យើងបានសម្រេចថាមានតែសំណងសមូហភាពដែលមិនមែនជាហិរញ្ញវត្ថុទេ ដែលអាចទាមទារបាន"។ មាននៅ http://www.eccc.gov.kh/english/cabinet/press/29/Joint_Press_Statement__on_internal_rules_eng_fr_13_june_2007.pdf, ចំណុចនេះមិនមែនមានន័យថាសំណងសមូហភាព មិនត្រូវមានតម្លៃជាប្រាក់ ដូចក្នុងឧទាហរណ៍ក្នុងវិធាន ២៣ ដូចជាការបោះពុម្ពផ្សាយសាលក្រមក៏ត្រូវចំណាយប្រាក់មួយចំនួនដែរ។

ជាពិសេសទៅទៀត ក្នុងពេលអនុម័តវិធានផ្ទៃក្នុងលើកទី១ ជនរងគ្រោះមិនទាន់បានដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយទេ។

១០១.សេចក្តីថ្លែងការណ៍របស់អ្នកជំនាញមួយរូបដែលចូលរួមធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង អាចជួយកំណត់និយមន័យពាក្យ "សំណងសមូហភាព និងសំណងផ្លូវចិត្ត" ដែលលោកបញ្ជាក់ថា៖ "ក្នុងកាលៈទេសៈនេះ ការបង្កើតមូលនិធិឯករាជ្យសម្រាប់គាំទ្រជនរងគ្រោះ ក្នុងគោលបំណងរៀបចំ**ទម្រង់សំណងសមូហភាព** ដូចជាការកសាងបូជនីយដ្ឋាន និង**ការផ្តល់សេវាព្យាបាលជំងឺផ្លូវចិត្ត** មិនត្រូវដកចេញពីនិយមន័យនេះឡើយ"[85] (សេចក្តីបញ្ជាក់បន្ថែម)។

១០២.អង្គការ REDRESS គឺជាអង្គការក្រៅរដ្ឋាភិបាលដែលមានជំនាញខាងស្វែងរកសំណងសម្រាប់ជនរងគ្រោះនៃអំពើទារុណកម្ម បានកំណត់និយមន័យសំណងសមូហភាពដូចតទៅនេះ៖ "ទម្រង់នៃសំណងសមូហភាព គ្រាន់តែជាវិធានការដែលត្រូវបានអនុម័តដើម្បីឆ្លើយតបទៅនឹងព្យសនកម្មដែលបានកើតឡើងចំពោះបុគ្គល ឬក្រុមមនុស្សច្រើនរួមគ្នា។ វិធានការរួមអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗ ដែលរាប់បញ្ចូលទាំងសេចក្តីត្រូវការខាងសម្ភារៈ បដិទាន និង/ឬ សំណងជានិមិត្តរូប"[86]។

១០៣.សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា អនុលោមតាមនិយមន័យនេះ ពាក្យថា "សមូហភាព" មិនមែនមានន័យថាសំណងប្រភេទនេះ មិនត្រូវឱ្យមានការចំណាយអ្វីសោះនោះទេ។ ជាពិសេស អង្គជំនុំជម្រះតុលាការកំពូល (អ.ត.ក) គួរសង្កត់ធ្ងន់លើអត្ថន័យនៃសំណងសមូហភាព ដែលត្រូវរាប់បញ្ចូលទាំងការគាំទ្រផ្លូវចិត្ត/សង្គម តាមរយៈវិធានការមួយចំនួន[87] និង

---

[85] អត្ថបទរបស់ Boyle, David មានចំណងជើងថា "សិទ្ធិរបស់ជនរងគ្រោះ (The Rights of Victims),' នៅក្នុង ' Journal of International Criminal Justice 4 (ឆ្នាំ2006), ទំព័រ307-313, ត្រង់ទំព័រ 312។

[86] អត្ថបទមានចំណងជើងថា "ការពិចារណាពីសំណងសំរាប់ជនរងគ្រោះនៃរបបខ្មែរក្រហម" អត្ថបទពិភាក្សារបស់គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា និង REDRESS, ខែវិច្ឆិកា ឆ្នាំ២០០៨, ត្រង់ទំព័រ8, http://www.unhcr.org/refworld/pdfid/4b388dcd2.pdf, ចូលមើលចុងក្រោយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១០។

[87] ដូចជើងទំព័រខាងលើ ទំព័រ10។

ជាវិធានការសមូហភាព ទោះបីជាបុគ្គលមួយចំនួននិងសមូហភាពទាំងមូលបានទទួលផលប្រយោជន៍ពីវិធានការនេះក៏ដោយ។

១០៤. ដូចគ្នានេះដែរ ទាំងនៅក្នុងច្បាប់ និងទ្រឹស្តីច្បាប់ គ្មាននិយមន័យជាក់លាក់ដែលកំណត់អត្ថន័យរបស់ពាក្យថា "សំណងផ្លូវចិត្ត"ឡើយ។ ដូច្នេះ ប្រសិនបើប្រកាន់យកអត្ថន័យតឹងរ៉ឹងក្នុងវិធានទាំងនេះ គ្មានមូលហេតុណាមួយដែលនាំឲ្យ អ.ត.ក *សន្និដ្ឋានជាមុនថា* អ.វ.ត.ក មិនអាចផ្តល់វិធានការសំណងជាសម្ភារៈ*ណាមួយ* នោះឡើយ។

១០៥. លើសពីនេះទៅទៀត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ឃើញថា ក្នុងវិធាន ២៣(១)(ខ) ពាក្យថា "សំណងសមូហភាពនិងសំណងផ្លូវចិត្ត" ត្រូវបានយកមកប្រើដើម្បីឲ្យច្បាស់ថា អ.វ.ត.ក មិនអាចផ្តល់សំណងហិរញ្ញវត្ថុសម្រាប់បុគ្គលម្នាក់ៗបានទេ។ វិធានផ្ទៃក្នុងមានចេតនាដកចេញនូវការអនុវត្តសំណងជាហិរញ្ញវត្ថុ តាមរយៈការប្រើពាក្យពេចន៍បែបនេះ។ អ.ត.ក គប្បីយល់ថា ពាក្យថា "សំណងផ្លូវចិត្ត" គឺជាសំណង "មិនមែនហិរញ្ញវត្ថុ"[88]។ អ.ត.ក ត្រូវតែចងចាំចេតនានេះ ក្នុងពេលខ្លួនវិភាគសំណើសុំសំណងរដ្ឋប្បវេណី។ ដូច្នេះ រាល់ការអនុវត្តសំណងដែលមិនមានគោលបំណងផ្តល់សំណងហិរញ្ញវត្ថុទៅឲ្យបុគ្គលម្នាក់ គឺបានបំពេញតាមលក្ខខណ្ឌនៃ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត"។ អាស្រ័យមូលហេតុដូចបានលើកឡើងខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា អ.ត.ក ត្រូវតែបែងចែកសំណងសមូហភាពនិងសំណងផ្លូវចិត្ត ចេញពីសំណងហិរញ្ញវត្ថុសម្រាប់បុគ្គល។

១០៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំនៅពេលដែលខ្លួនផ្តល់សំអាងហេតុថា ដោយសារខ្លួនមិនអាចដាក់កាតព្វកិច្ចទៅលើអាជ្ញាធរសុខាភិបាលជាតិបាន ខ្លួនមិនអាចសម្រេចផ្តល់សំណងតាមសំណើបែបនេះបានទេ។ ការសម្រេចផ្តល់សំណងតាមសំណើនេះ ក៏មិនមែនមានន័យថា ការផ្តល់ការព្យាបាលវេជ្ជសាស្ត្រត្រូវតែធ្វើឡើងដោយ អាជ្ញាធរសុខាភិបាលជាតិ ជាចាំ

---

88 អត្ថបទរបស់ Arturo J. Carrillo, មានចំណងជើងថា "សេចក្តីពន្យល់អំពីច្បាប់សិទ្ធិមនុស្សអន្តរអាមេរិកាំង" នៅក្នុង៖ សៀវភៅណែនាំស្តីពីសំណងរដ្ឋប្បវេណី មជ្ឈមណ្ឌលយុត្តិធម៌អន្តរកាល (ប្រែសម្រួល), បោះពុម្ពដោយ Oxford University Press, (ឆ្នាំ២០០៦), ទំព័រ 504-538 (512)។

បាច់នោះទេ។ ឧទាហរណ៍ល្អមួយ គឺអង្គការសុខភាពផ្លូវចិត្តនិងសង្គម (TPO) ដែលជាអង្គការក្រៅរដ្ឋាភិបាល និងផ្តល់សេវាថែទាំសុខភាពផ្លូវចិត្តដល់ជនរងគ្រោះ។

១០៧. តួនាទីនៃកម្មវិធីស្តារនីតិសម្បទាខាងវេជ្ជសាស្ត្រនិងផ្លូវចិត្តសមូហភាព គឺដើម្បីជួសជុលតែព្យសនកម្ម និងព្យាបាលការឈឺចាប់ដែលជនរងគ្រោះបានទទួលរង[89]។ ការស្តារនីតិសម្បទា មានគោលបំណងគាំទ្រជនរងគ្រោះ ដើម្បីឱ្យពួកគេបានជាសះស្បើយពីរបួសរាងកាយ ឬផ្លូវចិត្តដ៏ធ្ងន់ធ្ងរ និងកំណត់ទិសដៅអនាគតសម្រាប់ការព្យាបាលវេជ្ជសាស្ត្រ ដើម្បីថែទាំព្យាបាលរបួសរយៈពេលខ្លី/ជំងឺរ៉ាំរ៉ៃរបស់ជនរងគ្រោះ[90]។

១០៨. ជាពិសេស តុលាការអន្តរអាមេរិកាំងសម្រាប់សិទ្ធិមនុស្ស បានសម្រេចបង្គាប់ឱ្យសេវាកម្មព្យាបាលវេជ្ជសាស្ត្រ និងការថែទាំសុខភាពផ្លូវចិត្ត ជាទម្រង់នៃសំណងរដ្ឋប្បវេណី ដែលបានបញ្ជាក់ពីសារៈសំខាន់នៃសេវាកម្មទាំងនេះ[91]។ ក្នុងសាលក្រមស្តីពីសំណងរដ្ឋប្បវេណីរបស់ខ្លួន

---

[89] REDRESS, សំណងសមូហភាព (Collective Reparations): ទស្សនទាន & គោលការណ៍ , ទំព័រ 8, មាននៅ http://www.redress.org/downloads/events/CollectiveReparationsMG.pdf (បើកមើលចុងក្រោយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០)។

[90] Carrillo, យោងខាងលើ កំណត់សម្គាល់លេខ 96, ទំព័រ 512។

[91] ឧទាហរណ៍ IACHR 19 រឿងក្តី Merchants ទល់នឹង Colombia, សាលក្រម, Series C No. 109, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៤, អង្គសេចក្តី, សំណងនិងតម្លៃ, កថាខណ្ឌ275-278។ ក្នុងកថាខណ្ឌ 278 តុលាការសម្រេចថា "រដ្ឋមានកាតព្វកិច្ចផ្តល់ការព្យាបាលវេជ្ជសាស្ត្រនិងផ្លូវចិត្ត ដោយឥតគិតថ្លៃ តាមរយៈស្ថាប័នសុខាភិបាលរបស់ខ្លួន ជូនសាច់ញាតិរបស់ជនរងគ្រោះ ដោយរួមទាំងថ្លៃថ្នាំសង្កូវដែលគេត្រូវការផងដែរ (...) ចូរចងចាំយោបល់របស់អ្នកជំនាញ ដែលបានវាយតម្លៃ ឬព្យាបាលសាច់ញាតិរបស់ជនរងគ្រោះ (...) ថា ការព្យាបាលចិត្តសាស្ត្រត្រូវតែគិតគូរដល់កាលៈទេសៈពិសេស និងតម្រូវការរបស់សាច់ញាតិម្នាក់ៗ ដើម្បីពួកគេអាចទទួលបានការព្យាបាលជាសមូហភាព ជាគ្រួសារ ឬជាបុគ្គល ទៅតាមការព្រមព្រៀងរបស់ពួកគេ និងតាមការវាយតម្លៃរបស់បុគ្គលម្នាក់ៗ។ ក្នុងរយៈពេលមួយឆ្នាំ រដ្ឋ Colombia ត្រូវជូនដំណឹងដល់សាច់ញាតិរបស់ជនរងគ្រោះ ថាពួកគេត្រូវទៅទទួលការព្យាបាលវេជ្ជសាស្ត្រនិងផ្លូវចិត្តពីគ្រឹះស្ថានសុខាភិបាល ឬវិទ្យាស្ថានជំនាញណាមួយ។ ហើយរដ្ឋត្រូវតែជូនដំណឹងដល់ស្ថាប័នទាំងនោះឱ្យបានគ្រប់គ្រាន់ អំពីវិធានការនៃសំណងនេះ ដើម្បីឱ្យការព្យាបាលស្របតាមការបញ្ជាខាងលើ"។ នៅក្នុងកថាខណ្ឌ ២៨១-៤ តុលាការនេះបានសម្រេចថា "(...) រដ្ឋត្រូវតែផ្តល់ការព្យាបាលវេជ្ជសាស្ត្រនិងផ្លូវចិត្ត ដោយឥតគិតថ្លៃ តាមរយៈស្ថាប័នសុខាភិបាលរបស់ខ្លួន ជូនសាច់ញាតិរបស់ជនរងគ្រោះ ដោយ

00623081



តុលាការអន្តរអាមេរិកាំងសម្រាប់សិទ្ធិមនុស្ស បានពិនិត្យពិចារណាពី "សំណងជាហិរញ្ញវត្ថុ" និង "សំណងក្នុងទម្រង់ផ្សេងទៀត" នៅក្នុងផ្នែកមួយចំនួននៃសាលក្រម។ ការផ្តល់ការសេវាកម្មវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្ត ត្រូវបានពិភាក្សាក្នុងផ្នែកស្តីពី "សំណងរដ្ឋប្បវេណីក្នុងទម្រង់ផ្សេងទៀត"[92]។ អាស្រ័យហេតុនេះ តុលាការអន្តរអាមេរិកាំងសម្រាប់សិទ្ធិមនុស្ស ចាត់ទុកថា ការថែទាំវេជ្ជសាស្ត្រ និងការថែទាំសុខភាពផ្លូវចិត្ត គឺជាវិធានការសាកសមសម្រាប់ជួសជុលព្យសនកម្មដែលមិនមែនជាការខូចខាតផ្នែកហិរញ្ញវត្ថុ[93]។

១០៩. សំណើសុំសេវាកម្មព្យាបាលវេជ្ជសាស្ត្រ និងការថែទាំសុខភាពផ្លូវចិត្ត មិនមានគោលបំណងសុំឱ្យផ្តល់ជាចំនួនទឹកប្រាក់ទេ ប៉ុន្តែសុំឱ្យផ្តល់លទ្ធភាពប្រើប្រាស់សេវាទាំងនេះ។ នៅពេលដាក់សំណើ ដើមបណ្តឹងរដ្ឋប្បវេណីមិនមានចេតនាចង់បានសំណងហិរញ្ញវត្ថុជាបុគ្គលទេ ប៉ុន្តែចង់បានការផ្តល់សេវាកម្មដូចពោលខាងលើ។ ដូច្នេះ សំណើនេះបានទាមទារ "សំណងផ្លូវចិត្ត"។

១១០. លើសពីនេះទៅទៀត វិធានការដែលបានស្នើសុំក៏ជាវិធានការ "សមូហភាព" ផងដែរ។ សំណងសមូហភាពសង្កត់ធ្ងន់ទៅលើការផ្តល់ផលប្រយោជន៍ ទៅឱ្យក្រុមប្រជាពលរដ្ឋដែលរងគ្រោះពីការបំពានសិទ្ធិមនុស្ស[94]។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំវិធានការដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋមួយក្រុម ឬជា "សមូហភាព" នៃដើមបណ្តឹងរដ្ឋប្បវេណី ហើយត្រូវបែងចែកវិធានការនេះឱ្យដាច់ពីសំណងហិរញ្ញវត្ថុជាបុគ្គលដែលជាការជួសជុលការបាត់បង់ ឬការខូចខាតជាបុគ្គល។

---

រួមទាំងថ្លៃថ្នាំសង្កូវដែលគេត្រូវការផងដែរ (...)" ឧទាហរណ៍សូមមើលផងដែរ IACHR, រឿងក្តី Durand និង Ugarte តទល់នឹង Peru, សាលក្រមចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០១, សំណងនិងតម្លៃ, Series C No. 89, កថាខណ្ឌ 36, 37, 45-3, IACHR, រឿងក្តី Barrios Altos តទល់នឹង Peru, សាលក្រមចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០១, សំណងនិងតម្លៃ, Series C No. 87, កថាខណ្ឌ50-3។

[92] សូមមើឧទាហរណ៍ IACHR, រឿងក្តី Durand និង Ugarte តទល់នឹង Peru , យោងខាងលើ កំណត់សម្គាល់លេខ 99, ឬ IACHR, រឿងក្តី Barrios Altos តទល់នឹង Peru, យោងខាងលើ កំណត់សម្គាល់លេខ 99។

[93] IACHR 19 រឿងក្តី Merchants តទល់នឹង Colombia, សាលក្រម, យោងខាងលើ កំណត់សម្គាល់លេខ 99, កថាខណ្ឌ 253។

[94] យោងខាងលើ កំណត់សម្គាល់លេខ 97, ទំព័រ5។

១១១.ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានលើវិធាន ២៣(១)(ខ) ដោយសារការបកស្រាយខុសនូវសញ្ញាណនៃ "សំណងសមូហភាពនិងសំណងផ្លូវចិត្ត" ដែលនាំឱ្យខ្លួនពិចារណាថាសំណើខាងលើមិនស្ថិតក្នុងវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេចបាន។

## មូលដ្ឋានទី ១០៖ ការតម្រូវឱ្យបង្ហាញទំនាក់ទំនងរវាងការទាមទារនិង បទល្មើសដោយមិនមានមូលដ្ឋានច្បាប់គឺជាការបំពានវិធាន ២៣

១១២.អង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ទោះបីជាវិធាន ២៣(១)(ខ) អាចអនុញ្ញាតឱ្យមានការផ្តល់សំណងបែបនេះក៏ដោយ ក៏ភស្តុតាងត្រូវតែបង្ហាញឱ្យបានច្បាស់លាស់អំពីទំនាក់ទំនងនៃវិធានការដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ និងឧក្រិដ្ឋកម្មដែលពិរុទ្ធជន កាំង ហ្គេកអ៊ាវ ត្រូវទទួលខុសត្រូវ។ គ្មានភស្តុតាងបែបនេះត្រូវបានបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះឡើយ"[95]។

១១៣. អង្គជំនុំជម្រះសាលាដំបូងបានទាមទារឱ្យបង្ហាញទំនាក់ទំនងរវាងសំណើសុំសំណង និងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ដោយគ្មានផ្តល់មូលដ្ឋានច្បាប់គាំទ្រលក្ខខណ្ឌតម្រូវនេះឡើយ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានពិនិត្យទាំងនៅក្នុងវិធានផ្ទៃក្នុង និងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា តែមិនអាចរកឃើញមូលដ្ឋានច្បាប់ណាមួយដែលតម្រូវឱ្យបង្ហាញទំនាក់ទំនងនេះឡើយ។ ម្យ៉ាងវិញទៀត ទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិ គ្មានច្បាប់ណាមួយតម្រូវឱ្យបង្ហាញពីទំនាក់ទំនងនេះជាលក្ខខណ្ឌនៃការទាមទារសំណងឡើយ។ តាមរយៈការទាមទារឱ្យបង្ហាញទំនាក់ទំនងនេះ អង្គជំនុំជម្រះសាលាដំបូង បានបំពានលើសិទ្ធិទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបំពានលើវិធាន ២៣ នៃវិធានផ្ទៃក្នុង។

### ខ. សំណើទី ៧៖ ការថតសំឡេង និងថតវីដេអូ និងការផ្សព្វផ្សាយអំពីការជំនុំជម្រះ

១១៤.ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការផលិតឯកសារសោតទស្សន៍និងវីដេអូ នៃផ្នែកសំខាន់ៗនៃសវនាការ យ៉ាងហោចណាស់ឱ្យបាន ១០០ម៉ោង ដោយរួមទាំងរូបភាពវីដេអូបង្ហាញពីជនជាប់ចោទនៅថ្ងៃប្រកាសសាលក្រម។ ឯកសារសោតទស្សន៍និងវីដេអូ ត្រូវមានសេចក្តីពន្យល់ពីតួនាទីដើម

[95] សាលក្រម កថាខណ្ឌ៦៧៤។

បណ្តឹងរដ្ឋប្បវេណី ដោយផ្តល់សិទ្ធិឱ្យពួកគេកែសម្រួលខ្លឹមសារបានផង។ ត្រូវចែកផ្សាយឯកសារនេះ ៥ច្បាប់ សម្រាប់ការិយាល័យខេត្ត/ក្រុង និងឃុំ/សង្កាត់និមួយៗ។ ត្រូវចែកផ្សាយរូបថតសវនាការ យ៉ាងហោចណាស់ឱ្យបាន ១០សន្លឹក ទៅឱ្យគ្រប់ទីស្នាក់ការឃុំ/សង្កាត់ និងដាក់តាំងឯកសារជាលាយលក្ខណ៍អក្សរ និងខ្សែអាត់សំឡេងនៃសាលក្រមស្តាពរឱ្យបាន ១០ច្បាប់ គ្រប់វត្តអារាមក្នុងឃុំនីមួយៗ[96]។

១១៥.នៅក្នុងការវិភាគរបស់ខ្លួនលើសំណើសុំសំណងរដ្ឋប្បវេណី នៅត្រង់ផ្នែកនិយាយពី "សំណើសុំទាក់ទងនឹងការបោះពុម្ពផ្សាយសាលក្រមនិងការផ្សព្វផ្សាយ" អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួននឹងចេញសាលក្រមនឹងត្រូវចេញផ្សាយជាសាធារណៈ ហើយមាននៅលើគេហទំព័ររបស់ អ.វ.ត.ក ដែលប្រព័ន្ធផ្សព្វផ្សាយទាំងអស់អាចរកមើលបានបើមានបំណងយោងទៅលើសាលក្រមនេះ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ទៀតថា "ការផ្តល់ព័ត៌មានជាសាធារណៈ ស្តីពីសាលក្រមនឹងកើតមានជាលក្ខណៈនៃសកម្មភាពអប់រំផ្សព្វផ្សាយនៅក្នុសង្គមកម្ពុជាទាំងមូល និងការអប់រំសាធារណៈ"[97]។

១១៦.ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើសុំ "ការចងក្រងឯកសារនិងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយនូវផ្នែកនៃសាលក្រម... ដោយហេតុថាខ្វះភាពជាក់លាក់"[98]។

## មូលដ្ឋានទី ១១៖ ការបំពានលើវិធាន ២១(១)(ក)និង(គ) និង វិធាន ២៣

១១៧.ផ្ទុយពីសំអាងហេតុដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ សំណើសុំបានបញ្ជាក់ច្បាស់លាស់គ្រប់គ្រាន់ អំពីខ្លឹមសារនៃឯកសារនិងវិធីនៃការផ្សព្វផ្សាយផងដែរ[99]។ តាមរយៈការបដិសេធសំណើដោយផ្អែកលើមូលដ្ឋានថា ខ្វះភាពជាក់លាក់ ក្នុងករណីដែលសំណើបានចែងពិស្តារនិងជាក់លាក់បែបនេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានលើវិធាន ២១(១)(ក) និង(គ) និងវិធាន

[96] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៩។

[97] សាលក្រម កថាខណ្ឌ៦៦៩។

[98] *ដូចដើងទំព័រខាងលើ។*

[99] សូមមើល សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៩។

២៣ នៃវិធានផ្ទៃក្នុង។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់បញ្ចូលយោបល់នេះ ដោយយោងទៅរកទឡ្ហីករណ៍ក្នុងវាក្យខណ្ឌ ៦៨-៧៨ នៃបណ្តឹងឧទ្ធរណ៍នេះ។

១១៨. ការទាមទារឱ្យមានលក្ខខណ្ឌជាក់លាក់ ដោយគ្មានមូលដ្ឋានច្បាប់ដែលតម្រូវឱ្យមានលក្ខខណ្ឌនេះ ទាំងក្នុងវិធានផ្ទៃក្នុង និងច្បាប់អន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងមិនបានគោរពតាមភាពយុត្តិធម៌ នៃនីតិវិធី និងសិទ្ធិរបស់ជនរងគ្រោះ ហើយថែមទាំងបានបំពានលើ វិធាន ២១(១)(ក) និង (គ) និងវិធាន ២៣ នៃវិធានផ្ទៃក្នុងផងដែរ[100]។

១១៩. ជាពិសេសទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានបំពានលើវិធាន ២១(១)(ក) ដែលធានាឱ្យមានភាពយុត្តិធម៌នៃនីតិវិធី នៅពេលដែលខ្លួនដាក់បន្ទុកធ្ងន់ពេកមកលើដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ តាមរយៈការទាមទារនូវភាពជាក់លាក់ហួសហេតុ[101]។

## មូលដ្ឋានទី ១២៖ កំហុសអង្គហេតុ

១២០. តាមរយៈការបដិសេធសំណើដោយផ្អែកលើមូលដ្ឋានកង្វះភាពជាក់លាក់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោយមានកំហុសអង្គហេតុ។ អង្គជំនុំជម្រះសាលាដំបូងបានមើលរំលង និងមិនបានពិចារណាលើចំណុចពិស្តារសំខាន់ៗដែលសហមេធាវីបានដាក់ជូនខាងលើឡើយ។ សេចក្តីសម្រេចបដិសេធរបស់អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើកំហុសអង្គហេតុនេះ។
ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើចំណុចពិស្តារដែលសហមេធាវីបានដាក់ជូន អង្គជំនុំជម្រះសាលាដំបូងពិតបានទទួលស្គាល់ថាភាពជាក់លាក់ដែលខ្លួនទាមទារ ត្រូវបានផ្តល់ជូនគ្រប់គ្រាន់ហើយ។ តាមពិត កំហុសអង្គហេតុនេះនាំឱ្យមានកំហុសឆ្គងនៃយុត្តិធម៌ ដោយសារការសម្រេចនេះរារាំងមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណង[102]។

## ច. សំណើទី ៨÷ ការយកឈ្មោះជនរងគ្រោះទៅដាក់លើអគារសាធារណៈចំនួន ១៧

---

[100] *ដូចជើងទំព័រខាងលើ។*

[101] *ដូចជើងទំព័រខាងលើ។*

[102] សូមមើល កថាខណ្ឌ៨៤ និង ៨៥ នៃបណ្តឹងសាទុក្ខនេះ។

## និងការរំឭកដល់ជនរងគ្រោះ

១២១.ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំថាដើមបណ្តឹងរដ្ឋប្បវេណី គប្បីមានសិទ្ធិជ្រើសរើសអគារសាធារណៈ ដូចជាមន្ទីរពេទ្យ ឬសាលារៀនដើម្បីដាក់ឈ្មោះ ក្នុងនាមជនរងគ្រោះដែលខ្លួនតំណាងឱ្យ។ ដំណើរការនេះត្រូវមានពិធីបុណ្យសាធារណៈ និងការរំឭកវិញ្ញាណក្ខន្ធ ត្រូវចារឹកឈ្មោះជនរងគ្រោះនិងព័ត៌មានពីជោគវាសនារបស់ជនរងគ្រោះ។ ត្រូវមានសុន្ទរកថាដែលនិយាយពីរឿងរ៉ាវជនរងគ្រោះសម្រាប់អានក្នុងឱកាសនោះផងដែរ។ ត្រូវមានការផ្សព្វផ្សាយអំពីពិធីបុណ្យនេះ ហើយត្រូវរក្សាទុកឯកសារផ្សព្វផ្សាយនៅប្ញជនីយដ្ឋានទាំងបី[103]។ អង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចឆ្លើយតបនឹងសំណើនេះទេ។ អង្គជំនុំជម្រះគ្រាន់តែបានសម្រេចបញ្ហាទាក់ទិននឹង "វិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា"[104] តែប៉ុណ្ណោះ។

## មូលដ្ឋានទី ១៣៖ ការបំពានលើវិធាន ១០០(១)

១២២.តាមរយៈការមិនធ្វើសេចក្តីសម្រេចទៅលើសំណើនេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង។ សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងវិធានការរបស់រាជរដ្ឋាភិបាលកម្ពុជា មិនបានគ្របដណ្តប់ដល់សំណើនេះឡើយ។ ការវិភាគនេះយោងទៅរកតែសំណើសុំទិវារំឭកខួប និងការចេញសេចក្តីថ្លែងការណ៍សុំខមាទោសជាផ្លូវការតែប៉ុណ្ណោះ ប៉ុន្តែមិនបានឆ្លើយតបទៅនឹងសំណើសុំដាក់ឈ្មោះអគារសាធារណៈឡើយ។

១២៣. លើសពីនេះទៅទៀត ដូចបានពិភាក្សាក្នុងការកត់សម្គាល់បឋមខាងលើ[105] សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា គ្មានច្បាប់ណាហាមមិនឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចឱ្យជនជាប់ចោទផ្តល់ហិរញ្ញវត្ថុតាមសំណើនេះឡើយ ទោះបីយ៉ាងណាក៏ដោយ ត្រូវមានជំនួយខាងរដ្ឋបាល និងជំនួយមិនមែនហិរញ្ញវត្ថុពីរដ្ឋាភិបាលសម្រាប់អនុវត្តការទូទាត់សំណង។

---

[103] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ១៩។

[104] សាលក្រម កថាខណ្ឌ៦៧១។

[105] សូមមើល កថាខណ្ឌ២៥-២៨ នៃបណ្តឹងសាទុក្ខនេះ។

## មូលដ្ឋានទី ១៤៖ កំហុសអង្គហេតុ

១២៤.ជាពិសេសទៅទៀត ដោយសារការមិនចេញសេចក្តីសម្រេចលើសំណើនេះ សេចក្តីសម្រេចបដិសេធ បានផ្អែកលើកំហុសអង្គហេតុ។ តាមពិត កំហុសអង្គហេតុនេះនាំឱ្យមានកំហុសឆ្គងនៃយុត្តិធម៌ ដោយសារការសម្រេចនេះរារាំងមិនឱ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសំណង និងនាំឱ្យសាលក្រមគ្មានសុពលភាព។

## ង. សំណើទី ៩÷ ការធ្វើលិខិតជូនរដ្ឋាភិបាលដើម្បីសុំយកមួយចំណែកនៃថ្លៃចូលទស្សនា

១២៥.ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតសាធារណៈជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំឱ្យស្ថាប័ននេះចូលរួមក្នុងដំណើរការអនុវត្តសំណងដោយទុកមូលនិធិមួយចំណែកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេបានស្នើសុំឱ្យរាជរដ្ឋាភិបាលយក ១/៣ នៃថ្លៃចូលទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងជើងឯកសម្រាប់ផ្តល់ជាសំណងតាមសំណើដូចបានបញ្ជាក់ខាងលើ ហើយត្រូវយកមូលនិធិដែលសល់ពីនេះបែងចែកជាសំណងហិរញ្ញវត្ថុទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី[106]។

១២៦.អង្គជំនុំជម្រះសម្រេចថាការបង្កើតមូលនិធិក្នុងភារៈគ្រប់គ្រងសម្រាប់ជនរងគ្រោះ គឺលើសពីវិសាលភាពនៃប្រភេទសំណងដែល អ.វ.ត.ក អាចសម្រេចបាន[107]។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្នើសុំសេចក្តីសម្រេចបង្គាប់ឱ្យបង្កើតមូលនិធិនេះទេ ប៉ុន្តែបានសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យជនជាប់ចោទ សរសេរលិខិតសាធារណៈជូនរាជរដ្ឋាភិបាលកម្ពុជាដើម្បីឱ្យរាជរដ្ឋាភិបាលយក ១/៣ នៃថ្លៃចូលទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងជើងឯកសម្រាប់ជាសំណងហិរញ្ញវត្ថុទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី។ ការបង្គាប់ឱ្យជនជាប់ចោទសរសេរសំបុត្រជូនរាជរដ្ឋាភិបាល គឺស្ថិតនៅក្នុងវិសាលភាពនៃប្រភេទសំណងសមូហភាពនិងសំណងផ្លូវចិត្តដែល អ.វ.ត.ក អាចសម្រេចបាន។

---

[106] សេចក្តីសន្និដ្ឋានបញ្ចប់, កថាខណ្ឌ២០។

[107] សាលក្រម កថាខណ្ឌ៦៧០។

១២៧.ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចទៅលើសំណើសុំឱ្យបង្គាប់ឱ្យជនជាប់ចោទ សរសេរលិខិតសាធារណៈជូនរាជរដ្ឋាភិបាលកម្ពុជាទាល់តែសោះ។

## មូលដ្ឋានទី ១៥៖ ការបំពានលើវិធាន ១០០(១)

១២៨.តាមរយៈការមិនចេញសេចក្តីសម្រេចលើសំណើដែលបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតជូនរាជរដ្ឋាភិបាល អង្គជំនុំជម្រះសាលាដំបូងបានបំពានលើវិធាន ១០០(១) នៃវិធានផ្ទៃក្នុង ដែលចែងថា "អង្គជំនុំជម្រះត្រូវចេញសេចក្តីសម្រេចពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម"។

## មូលដ្ឋានទី ១៦៖ កំហុសអង្គហេតុ

១២៩.តាមរយៈការមិនធ្វើសេចក្តីសម្រេចអ្វីសោះលើសំណើនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គហេតុ ដែលនាំឱ្យមានកំហុសឆ្គោយនៃយុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងពេលខ្លួនពិចារណាថាសំណើនេះស្ថិតក្នុង "សំណើសុំវិធានការពីរាជរដ្ឋាភិបាល" ឬ "សំណើសុំបង្កើតមូលនិធិភារៈគ្រប់គ្រង"។ ការយល់មិនត្រឹមត្រូវលើសំណើនេះ បង្កើតបានជាកំហុសអង្គហេតុដែលនាំឱ្យមានកំហុសឆ្គោយនៃយុត្តិធម៌។ តាមពិត អង្គជំនុំជម្រះសាលាដំបូងមានសមត្ថកិច្ចក្នុងការបង្គាប់ឱ្យ កាំង ហ្គេកអ៊ាវ សរសេរលិខិតជូនរាជរដ្ឋាភិបាល ប៉ុន្តែខ្លួនបានធ្វើមិនដឹងមិនឮពីអង្គហេតុនេះនៅក្នុងសំណើ[108]។ ជាថ្មីម្តងទៀត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការភ្ញាក់ផ្អើល សូម្បីតែសំណើមានអត្ថន័យច្បាស់និងន័យត្រង់បែបនេះ ក៏អាចធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ខុសបានដែរ។

១៣០.ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានមើលរំលងអត្ថន័យដ៏ច្បាស់ក្នុងសំណើ និងយល់ច្រឡំពីអង្គហេតុដែលនាំឱ្យមានកំហុសឆ្គោយនៃយុត្តិធម៌។

## សេចក្តីសន្និដ្ឋាន និងសំណើ

១៣១. អាស្រ័យមូលហេតុដូចបានបញ្ជាក់ខាងលើ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការបកស្រាយច្បាប់/វិធានផ្ទៃក្នុង និងមាន

[108] សូមមើល កថាខណ្ឌ៥៨ និង៥៩ នៃបណ្តឹងសាទុក្ខនេះ។

កំហុសអង្គហេតុដែលនាំឲ្យមានកំហុសឆ្គោយនៃយុត្តិធម៌ និងធ្វើឲ្យផ្នែកនៃសាលក្រមដែលពាក់ព័ន្ធនឹងសំណើសុំសំណងរដ្ឋប្បវេណីក្លាយទៅជាគ្មានសុពលភាព។

ហេតុដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើសុំដោយក្តីគោរពដល់ អង្គជំនុំជម្រះតុលាការកំពូល ដើម្បីសម្រេច៖

- ប្រកាសថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន
- បដិសេធសាលក្រមរឿងក្តី ០០១ ត្រង់ផ្នែកពាក់ព័ន្ធនឹងសំណងរដ្ឋប្បវេណី
- ប្រកាសផ្តល់សំណងរដ្ឋប្បវេណីទាំងស្រុងតាមសំណើសុំទាំងអស់។

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃ២ ខែវិច្ឆិកា ឆ្នាំ២០១០

សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី

លោក ហុង គឹមសួន | លោក គង់ ពិសី

លោក យុង ផានិត | កញ្ញា Silke STUDZINSKY